# នមស្ការព្រះរតនត្រ័យ
# និង
# កំណាព្យសំរាប់សិស្សនិងនិស្សិត
## វគ្គទី១ ទី២ ទី៣ ទី៤




ដោយ
ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ**

ព.ស.២៥៥៥ គ.ស.២០១១

www.hoksavann.org

ចែកជាធម្មទាន

# ប្រវត្តិរូបសង្ខេប
# ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណា

ឈឈឈ❁ឈឈឈ

ប្រសូត ថ្ងៃ១០មីនា១៩៤០ នៅឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា, ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា** ជាបុត្រទី៣ក្នុងបណ្ដាបុត្រទាំង៥នាក់ បិតានាម **ហុក ហៃ** មាតានាម **សុខ ឃឹម**។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរលុះព្រះជន្ម២១ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ។ កាលប្រព្រឹត្តការណ៍ឆ្នាំ១៩៧៥ ព្រះអង្គបានភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបានទៅរស់នៅទីក្រុងម៉ុងរេ-អាល់ ប្រទេសកាណាដា នៅថ្ងៃ២៣មេសា១៩៨១។

កាលពីកុមារភាព ព្រះអង្គបានសិក្សាអក្សរសាស្រ្តជាតិចប់បឋមសិក្សា។ ពេលចូលកាន់ផ្នួស ព្រះអង្គបានសិក្សាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក បានសិក្សានៅពុទ្ធិកសិក្សា ជាប់ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យម

សិក្សាបឋមភូមិនិងទុតិយភូមិ និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។ ឆ្លៀតទៅរៀនអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ។ ក្រៅពីសិក្សាគន្ថធុរៈ ព្រះអង្គបានប្រតិបត្តិវិបស្សនាធុរៈអស់ជាច្រើនឆ្នាំ។ នៅបរទេស ព្រះអង្គបានសិក្សាបន្តជាប់អនុបណ្ឌិត (Master´s degree) ទីបំផុត ជាប់បណ្ឌិតទស្សនាវិជ្ជាផ្នែកព្រះពុទ្ធសាសនា (Doctor of Philosophy on Buddhism) នៅសាកលវិទ្យាល័យញូដែល្លី នៃប្រទេសឥណ្ឌា នៅថ្ងៃ២៨កុម្ភៈ២០០៤។

នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស ព្រះអង្គបានជួយ សង្គមខ្មែរយ៉ាងច្រើនផ្នែកបញ្ញាស្មារតី ដោយវិធីទេសនាពន្យល់តាមមាគ៌ាព្រះពុទ្ធសាសនា។

# មាតិកាអត្ថបទ

## នមស្ការសង្ខេប


| | |
|---|---|
| ១. នមស្ការសង្ខេប | ១ |
| ២. របៀបសមាទាននិច្ចសីល (សីល៥) | ៧ |
| ៣. វិធីសមាទានឧបោសថសីល (សីល៨) | ១៤ |
| ៤. ការសុំខមាទោសព្រះរតនត្រ័យ | ២០ |
| ៥. ពាក្យសូមខមាទោស | ២០ |
| ៦. ពាក្យថ្វាយខ្លួន | ២២ |
| ៧. អារាធនាព្រះសង្ឃចំរើនព្រះបរិត្ត | ២៣ |
| ៨. អារាធនាព្រះធម៌ទេសនា | ២៤ |
| ៩. ពាក្យអារាធនាទេសនាមួយបែបទៀត | ២៦ |
| ១០. នមស្ការបូជនីយវត្ថុ | ២៧ |
| ១១. អនុមោទនារក្ខាយាចនគាថា | ២៨ |
| ១២. ពិធីវេរភត្តប្រគេនព្រះសង្ឃ | ២៩ |
| ១៣. ពិធីវេរបច្ច័យ៤ប្រគេនព្រះសង្ឃ | ៣១ |
| ១៤. វេរផ្កាហិរញ្ញវត្ថុ | ៣២ |

១៥. ឧទ្ទិសទាន ៣៣
១៦. វេរកឋិនទានដល់ព្រះសង្ឃ ៣៤
១៧. វេរគ្រឿងបរិក្ខារជាបរិវារកឋិន ៣៤
១៨. វេរកឋិនទានមួយបែបទៀត ៣៥
១៩. តេជះខ្ញុំសាង ៣៦
២០. បត្តិទានគាថា ៣៧
២១.ការប្រកាសពុទ្ធាភិសេក ៣៧
២២.ការប្រកាសមាឃបូជា ៣៨
២៣.ការប្រកាសពិសាខបូជា ៣៩
២៤.ការតាំងចិត្តពេលធ្វើកុសល ៤០

# នមស្ការសង្ខេប

## Brief Homage to Triple Gem

នមោ តស្ស ភគវតោ អរហតោ
namo tassa bhagavato arahato
សម្មាសម្ពុទ្ធស្ស។ (សូត្រ៣ដង)
sammāsambudhassa. (3times)
ថ្វាយបង្គំម្តង។

- Homage to the Exalted One, the Worthy One, the Perfectly Enlightened One.

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ
Itipi so bhagavā arahaṇ samāsambuddho
វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ
vijjācaranasampanno sugato lokavidū anuttaro
បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ
purisadammasarathi satthā devamanussānaṇ
ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ
buddho bhagavāti taṇ arahatikunasamyutaṇ

ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ
buddaṇ sirisā namāmi tañca buddaṇ imehi
សក្ការេហិ អភិបូជយាមិ។
sakkārehi abhipūjayāmi.

- Such, indeed, is the Exalted One, worthy, perfectly enlightened, endowed with knowledge and conduct, well-gone, knower of worlds, incomparable (with excellent qualities, such as virtue, etc.) trainer of persons capable of training, teacher of gods and men, enlightened, exalted. With my head I do homage to the Buddha, who is endowed with such excellent qualities as arahantship, etc. and I honor the Buddha with these offerings.

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ
Svākhāto bhagavatā dhammo sanditthiko
អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ
akāliko ehipassiko opanayiko paccattaṇ
វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិ គុណសំ
veditabbo viññūhīti taṇ svākhātāti kunasaṇ
យុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ
yutaṇ dhamman sirisā namāmi tañca dhamman

ឥមេហិ សក្ការេហិ អភិបូជយាមិ។

imehi sakkārehi abhipūjayāmi.

ថ្វាយបង្គំម្តង។

- Well expounded by the Exalted One is the Dhamma, visible here and now, immediately effective, inviting investigation, leading onward, to be realized by the wise, each for himself. With my head I do homage to the Dhamma, which is endowed with such excellent qualities as being well expounded, etc. and I honor the Dhamma with these offerings.

សុបដិបន្នោ ភគវតោ សាវកសង្ឃោ

Supatipanno bhagavato sāvakasaṇgho

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ

ujupatipanno bhagavato sāvakasaṇgho

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ

ñāyapatipanno bhagavato sāvakasaṇgho

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ

sāmīcipatipanno bhagavato sāvakasaṇgho

យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា
yatidaṇ cattāri purisayugāni attha purisapuggalā
ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ
esa bhagavato sāvakasaṇgho āhuneyyo
បាហុនេយ្យោ ទក្ខិនេយ្យោ អញ្ជលិករណីយោ
pāhuneyyo dakkhineyyo añjalikaranīyo
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ
anuttanraṇ puññakkhettaṇ lokassāti taṇ
សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា
supatipannātikunasamyutaṇ sanghaṇ sirisā
នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ
namāmi tañca sanghaṇ imehi sakkārehi
អភិបូជយាមិ។
abhipūjayāmi.
ថ្វាយបង្គំម្តង។

- Of good practice is the Order or Disciples of the Exalted One; of straight practice is the Order of Disciples of the Exalted One; of right practice is the Order of Disciples of the Exalted One; of proper practice is the Order of Disciples of the Exalted One; thus, these four

pairs of persons, the eight kinds of individuals, this Order of Disciples of the Exalted One is worthy of offering, worthy of hospitality, worthy of gifts, worthy of reverential salutation, is an incomparable field of merit for the world. With my head I do homage to the Sangha, which is endowed with such excellent qualities as being of good practice, etc. and I honor the Sangha with these offerings.

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ

Iccevamaccanta namassaneyyaṇ namasamāno

រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ

ratanattayaṇ yaṇ puññābhisantaṇ vipulaṇ alatthaṇ

តស្សានុភាវេន ហតន្តរាយោ។

tassānubhāvena hatantarāyo.

ថ្វាយបង្គំ៣ដង។

(bow three times)

- I have gained an abundant flood of merit thus honoring the Triple Gem most hightly worthy of respect; by the spiritual power of that (merit) may (my) obstacles be destroyed.

# សេចក្ដីប្រែ

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសារធំទូលាយ។
សូមឲ្យកំចាត់បង់ អព្វមង្គលទាំងឡាយ
ឲ្យចៀសចេញចាកឆ្ងាយ ក្ដីអន្តរាយកុំបីមាន។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុណ្យរាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង។

ថ្វាយបង្គំម្តង

# របៀបសមាទាននិច្ចសីល (សីល៥)

The Method of asking for the five precepts (Niccasila)

ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

Ukāsa mayaṇ bhante visuṇ visuṇ rakkhanatthāya

តិសរណេន សហ បញ្ច សីលានិ យាចាម។

tisaranena saha pañca sīlāni yācāma.

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

Dutiyampi mayaṇ bhante visuṇ visuṇ rakkhanatthāya

តិសរណេន សហ បញ្ច សីលានិ យាចាម។

tisaranena saha pañca sīlāni yācāma.

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

Tatiyampi mayaṇ bhante visuṇ visuṇ rakkhanattāya

តិសរណេន សហ បញ្ច សីលានិ យាចាម។

tisaranena saha pañca sīlāni yācāma.

- Permit us, venerable sir, we ask for the Five Precepts with the Three Refuges in order to observe them separately. Venerable sir, kindly minister the Precepts to us. For the second time, venerable sir, we ask for the Five Precepts with the Three Refuges in order to observe them separately. Venerable sir, kindly minister the Precepts to us. For the third time, venerable sir, we ask for the Five Precepts with the Three Refuges in order to observe them separately. Venerable sir, kindly minister the Precepts to us.

អ្នកសមាទានត្រូវទទួលតាមព្រះសង្ឃថា៖

The lay people repeat after the monk:

នមោ តស្ស ភគវតោ អរហតោ

Namo tassa bhagavato arahato

សម្មាសម្ពុទ្ធស្ស (បីចប់)

sammāsambuddhassa. (3times)

- Homage to the Exalted One, the Worthy One, the Perfectly Enlightened One.

ពុទ្ធំ សរណំ គច្ឆាមិ ។
Buddhaṇ saranaṇ gacchāmi.
ធម្មំ សរណំ គច្ឆាមិ ។
Dhammaṇ saranaṇ gacchāmi.
សង្ឃំ សរណំ គច្ឆាមិ ។
Sanghaṇ saranaṇ gacchāmi.
I go to the Buddha as my refuge.
I go to the Dhamma as my refuge.
I go to the Sangha as my refuge.

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ។
Tutiyampi Buddhaṇ saranaṇ gacchāmi.
ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ។
Tutiyamipi Dhammaṇ saranaṇ gacchāmi.
ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។
Tutiyamipi Sanghaṇ saranaṇ gacchāmi.
- For the second time,
I go to the Buddha as my refuge.
For the second time,
I go to the Dhamma as my refuge.
For the second time,
I go to the Sangha as my refuge.

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ។

Tatiyampi Buddhaṇ saranaṇ gacchhāmi.

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ។

Tatiyampi Dhammaṇ saranaṇ gacchhāmi.

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។

Tatiyampi Sanghaṇ saranaṇ gacchhāmi.

-For the third time,
I go to the Buddha as my refuge.
For the third time,
I go to the Dhamma as my refuge.
For the third time,
I go to the Sangha as my refuge.

## ភិក្ខុអ្នកប្រទានសីលរំលឹកថា

The monk then says:

តិសរណគ្គហណំ បរិបុណ្ណំ

Tisaranaggahanaṇ Baribunnam.

This ends the going for refuge.

ទទួលថាៈ អាម ភន្តេ។

The lay people respond: Āma Bhante.

(yes, venerable, sir)

## អ្នកទទួលត្រូវថាតាមតទៅទៀត

The monk then recites the precepts line by, with the lay people reciting them line by line after him.

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

Pānātipātā veramanī sikkhāpadaṇ samādiyāmi.

I accept the precept to abstain from the taking of any living being.

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

Adinnādānā veramanī sikkhāpadaṇ samādiyāmi

I accept the precept to abstain from the taking of what is not given.

កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ

Kāmesu micchācārā veramanī sikkhāpadaṇ samādiyāmi

I accept the precept to abstain from sexual misconduct.

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

Musāvādā veramanī sikkhāpādaṇ samādiyāmi

I accept the precept to abstain from telling lies.

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី

Surāmerayamajjapamātatthānā veramanī

សិក្ខាបទំ សមាទិយាមិ

sikkhāpādaṇ samādiyāmi

I accept the precept to abstain from drinking that cause intoxication.

ភិក្ខុអ្នកប្រទានសីលពោលរំលឹកថាៈ

The monk then concludes with the following:

ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា

Imāni pañca sikkhāpadāni sādhukaṇ katvā

អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ។

appamātena niccalālaṇ sammārakkhitappan.

These are the five training rules.

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ។

The lay people respond: Āma Bhante.

Yes, Venerable Sir.

លោកសំដែងអានិសង្សសីលថា

សីលេន សុគតឹ យន្តិ

Sīlena sugatiṇ yanti.

Through virtue they go to a good birth.

សីលេន ភោគសម្បទា

Sīlena phogasampadā.

Through virtue is wealth attained.

សីលេន និព្វុតឹ យន្តិ

Sīlena nipputiṇ yanti.

Through virtue they go to liberation.

តស្មា សីលំ វិសោធយេ។

Tasmā sīlaṇ visodhaye.

Therefore we should purify our virtue.

អ្នកសមាទានទទួលថាៈ សាធុ (បីដង)

The lay people respond: Sādhu (three times)

(ថ្វាយបង្គំបីដង)

(BOW THREE TIMES)

ចប់សមាទាននិច្ចសីលតែប៉ុណ្ណោះ

# វិធីសមាទានឧបោសថសីល ( សីល៨ )

The Eight Precepts

(បើសមាទានគ្នាច្រើនថា)

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ។

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ។

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ។

(បើសមាទានតែម្នាក់ឯងថា)

ឱកាស អយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ។

តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ។

អ្នកសមាទានត្រូវទទួលតាមព្រះភិក្ខុថាៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

(៣ចប់)

ពុទ្ធំ សរណំ គច្ឆាមិ។

ធម្មំ សរណំ គច្ឆាមិ។

សង្ឃំ សរណំ គច្ឆាមិ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ។

(ចប់ត្រៃសរណគមន៍តែប៉ុណ្ណោះ។)

ភិក្ខុអ្នកប្រទានសីលថា:

តិសរណគ្គហណំ បរិបុណ្ណំ។

អ្នកសមាទានទទួលថា:

អាម ភន្តេ។

អ្នកទទួលត្រូវថាតាមដូចតទៅៈ

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ។

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ។

អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។

វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ។

នច្ច គីត វាទិត វិសូកទស្សន មាលា គន្ធ វិលេបន ធារណ មណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។

ឧច្ចាសយន មហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ។

អ្នកសមាទានសូត្រកំណត់ឧបោសថកាលថា:

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ
ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ
សម្មទេវអភិរក្ខិតុំ សមាទិយាមិ។

- ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីលដ៏ប្រកបព្រមដោយអង្គ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូរណ៍ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឲ្យច្បាស់នូវព្រះនិព្វាន ឰដ៏អនាគតកាលទៅឯមុខនោះហោង។

ព្រះសង្ឃរំលឹកថា:

ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ។

អ្នកសមាទានទទួលថាៈ អាម ភន្តេ។

ភិក្ខុអ្នកប្រទានសីលសំដែងអានិសង្សសីលថាៈ

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ។

អ្នកសមាទានត្រូវទទួលថា សាធុ (៣ដង) ។
(ចប់ការសមាទានឧបោសថសីលតែប៉ុណ្ណោះ។)

# ការសុំខមាទោសព្រះរតនត្រ័យ

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ។

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ។

(ក្រាបថ្វាយបង្គំម្តង។)

# ពាក្យសូមខមាទោស

អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តេសំ នោ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគណ្ហាន្តុ អាយតឹ សំវរាយ។

បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ទោសកំហុសដែលប្រព្រឹត្តកន្លងគ្រប់សង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះករុណាទាំងឡាយដ៏ចំរើនក្រែងខ្ញុំព្រះករុណាទាំងឡាយបានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមព្រះករុណាទាំងឡាយ អត់ទោសកំហុសនោះដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឲ្យល្អទៅខាងមុខនោះហោង។

# ពាក្យថ្វាយខ្លួន

មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ ឧបាសិកាយោ នោ ភគវា ធារេន្តុ អជ្ជតគ្គេ បាណុបេតេ បាណុបេតា សរណំ គតេ សរណំ គតា។

បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគដែលបរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះករុណាទាំងឡាយ ជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសកឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅហោង។

◈◈◈◈◈

# អារាធនាព្រះសង្ឃចំរើនព្រះបរិត្ត

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ។
វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ។
វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ។

ប្រែថាៈ សូមព្រះករុណាទាំងឡាយចំរើននូវព្រះបរិត្តជាជយមង្គល ដើម្បីការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំងទុក្ខ ភ័យ រោគទាំងអស់ឲ្យវិនាសបាត់ទៅហោង។

☆☆☆☆☆

# អារាធនាព្រះធម៌ទេសនា

ព្រហ្មា ច លោកាធិបតី សហម្បតី
កតញ្ជលី អន្ធិវរំ អាយាចថ។
សន្តីធ សត្តាប្បរជក្ខជាតិកា
ទេសេតុ ធម្មំ អនុកម្បិមំ បជំ។
សទ្ធម្មភេរី វិនយញ្ច កាយំ
សុត្តញ្ច ពន្ធំ អភិធម្ម ចម្មំ។
អាកោដយន្តោ ចតុសច្ចទណ្ឌំ
បញ្ចោធនេយ្យេ បរិសាយ មជ្ឈេ។

សហម្បតីព្រហ្ម ឱនបង្គំអារាធនា
សម្តេចព្រះភគវា ដោយគាថាយ៉ាងនេះឯង។
ព្រះពុទ្ធទ្រង់អនុក្ខូល ព្រមទទួលនឹងសំដែង
ដោយតុណ្ហីភាពថ្លែង តាមភាវៈគុណករុណា។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ។

ញុំាងសត្វចូលពុទ្ធចក្រ មានបញ្ញវត្តិយ៍ជាអាទិ៍
ឲ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា។
ចាប់ដើមពីនោះឯង ទ្រង់សំដែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រ័យ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឲ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង។

★★★★★

# ពាក្យអារាធនាទេសនាមួយបែបទៀត

អហំវីខ្ញុំម្ចាស់ សូមឱកាសក្រាបប្រណិប័តន៍
ដល់អស់ពួកបរិស័ទ ដែលលះកាត់ក្ដីកង្វល់។
ហើយមកប្រជុំគ្នា ព្រោះប្រាថ្នាយកកុសល
ហេតុនេះសូមដំកល់ តាំងចិត្តស្ដាប់ធម៌ទេសនា។
ដើម្បីជាការបុណ្យ និងជាគុណច្រើនណាស់ណា
អំណាចស្ដាប់ទេសនា ដោយជ្រះថ្លាក្នុងសន្ដាន។
សូមតាំងចិត្តឲ្យស្អាត ខ្ញុំអារាធនាថ្កាន
និមន្តលោកនិទាន ទេសន៍ទូន្មានយើងរាល់គ្នា។
ពេលនេះសូមបរិស័ទ ដែលប្រណិប័តន៍គាល់ត្រៀបត្រា
កុំពោលកុំចរចា និយាយគ្នាបែរមុខក្រោយ។
សូមផ្ចង់នូវសញ្ញា ផ្ទៀងសោតាស្ដាប់កុំធ្វេស
ទើបនឹងបានផលសោយ អានិសង្ស៥ប្រការ។

*****

# នមស្ការបូជនីយវត្ថុ

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ
សារីរិកធាតុ មហាពោធឹ ពុទ្ធរូបំ សកលំ សទា។

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតីយ៍
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្រ។
សូមទាន់ព្រះអរិ- យមេត្រីថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង។

※※※※※

# អនុមោទនារក្ខាយាចនគាថា

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា។

# ពិធីវេរភត្តប្រគេនព្រះសង្ឃ

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស ឥមំ សង្ឃភត្តំ សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ ឥមំ សង្ឃភត្តំ អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន។

ទុតិយម្បិ...។ តតយម្បិ...។

បពិត្រព្រះសង្ឃដ៏ចំរើន រីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយសូមឧទ្ទិសចំពោះលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ហើយសូមវេរនូវសង្ឃភត្តនេះ ព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធរូបស្នងព្រះអង្គជាប្រធាន សូមលោកអ្នកដ៏មាន

គុណទាំងឡាយមានមាតានិងបិតាជាដើមនោះ សំគាល់នូវសង្ឃភត្តនេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយសូមឲ្យរួចរដោះ ចាកទុក្ខទាំងពួង ឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ៣ប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនមកមិនដាច់នេះហោង។

អស់វារៈ២ដងផង។ អស់វារៈ៣ដងផង។

❁❁❁❁❁

# ពិធីវេរបច្ច័យ៤ប្រគេនព្រះសង្ឃ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ មាតាបិតុអាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។

ទុតិយម្បិ... តតិយម្បិ...។

បពិតព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ៤នេះ មកតម្កល់ទុកក្នុងទីនេះ ហើយវេរប្រគេន ដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវបច្ច័យទាំងឡាយ៤នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រ-យោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង។

អស់វារៈ២ដងផង។ អស់វារៈ៣ដងផង។

# ចេវផ្កាហិរញ្ញវត្ថុ

មយំ ភន្តេ សទ្ធាបសន្នា ឥជ អារាមេ (សេនាសនករណត្ថាយ) ឥមានិ ហិរញ្ញបុប្ផានិ ឥធានេត្វា សង្ឃស្ស បវារេម។

សាធុ ភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ ឋបិតានិ ឥមានិ ហិរញ្ញបុប្ផានិ បដិជានាតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។

ទុតិយម្បិ...។ តតិយម្បិ...។

បពិត្រព្រះសង្ឃព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយមានសទ្ធាជ្រះថ្លា បាននាំមកនូវផ្កាហិរញ្ញវត្ថុទាំងឡាយនេះ សូមបវារណាចំពោះព្រះសង្ឃ (ដើម្បីកសាងសេនាសនៈ) ក្នុងវត្តនេះ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលដឹងនូវផ្កា ហិរញ្ញវត្ថុទាំងឡាយនេះ ដែលយើងខ្ញុំទាំងឡាយ បានទុកដាក់ហើយ ក្នុងដៃនៃកប្បិយការកៈដ៏សមគួរដល់វិន័យ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រ-យោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង។

អស់វារៈ២ដងផង។ អស់វារៈ៣ដងផង។

## ឧទ្ទិសទាន

ឥទំ វោ ញាតីនំ ហោតុ

សុខិតា ហោន្តុ ញាតយោ។

ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយដល់នូវសេចក្តីសុខ។

## ទេរកឋិនទាន ដល់ព្រះសង្ឃ

ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម។

ទុតិយម្បិ...។ តតិយម្បិ...។

បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ប្រគេន ចំពោះព្រះសង្ឃ។

អស់វារៈ២ដងផង។ អស់វារៈ៣ដងផង។

ត្រង់ ទុស្សំ អាចដាក់ថា វត្ថុំ ក៏បាន។

## ទេរគ្រឿងបរិក្ខារជាបរិវារកឋិន

យេនម្ហាកំ គហិតំ កឋិនំ កឋិនានិសំសានិ តស្សេវ ទេម។ ទុតិយម្បិ...។ តតិយម្បិ...។

បពិតព្រះសង្ឃដ៏ចំរើន រីកឋិនទាននៃយើងខ្ញុំ ទាំងឡាយ គឺលោកម្ចាស់អង្គណាបានទទួលកាន់ យកហើយ យើងខ្ញុំទាំងឡាយសូមវេរនូវគ្រឿងបរិក្ខារ ជាបរិវារនៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់ អង្គនោះ។ អស់វារៈ២ដងផង។ អស់វារៈ៣ដងផង។

# វេរកឋិនទានមួយបែបទៀត

ឥមំ ភន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ទេម

សាធុ នោ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសង្សំ

បដិគ្គណ្ហាតុ កឋិនំ អត្ថរិតុំ មាតាបិតុអាទីនញ្ច

គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ

សុខាយ។ ទុតិយម្បិ...។ តតិយម្បិ...។

បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយសូមវេរប្រគេននូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភដល់ព្រះសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃមេត្តាទទួលយក នូវកឋិនចីវររបស់យើងខ្ញុំទាំងឡាយនេះ ព្រមទាំងអានិសង្សលាភដើម្បីក្រាលកឋិន ដើម្បីសេចក្ដីចំរើន, ដើម្បីជាប្រយោជន៍, ដើម្បីសេចក្ដីសុខ, ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង, ដល់យើងខ្ញុំទាំងឡាយផងអស់កាលជាយូរអង្វែងទៅហោង។

អស់វារៈ២ដងផង។ អស់វារៈ៣ដងផង។

# តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន។
គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតយល់ត្រូវ តាមផ្លូវនិព្វាន មគ្គផលជាស្ពាន
ដល់ឋានថ្លៃថ្លា។
សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណឧបជ្ឈាយ៍ គុណគ្រូអាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
សូមជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ឋានផុតទុក្ខ។
ខ្ញុំសូមប្រាថ្នា សច្ចវាចា តទៅខាងមុខ
សូមមានប្រាជ្ញា ភ្លឺថ្លាមុះមុត សូមឆ្លងផុតទុក្ខ
ដល់និព្វានហោង។

*****

# បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ    កត្តព្វំ កិរិយំ មម
កាយេន  វាចា  មនសា  តិទសេ  សុគតំ  កតំ
យេ  សត្តា  សញ្ញិនោ  អត្ថិ  យេ  ច  សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ    សព្វេ ភាគី ភវន្តុ តេ
យេ តំ កតំ សុវិទិតំ    ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ    ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា  ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ    លភន្តុ មម ចេតសាតិ។

# ការប្រកាសពុទ្ធាភិសេក

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !
ព្រះពុទ្ធមានសិរីទ្រង់ឈ្នះអើយ !
មារស្ស ច បាបិមតោ បរាជយោ !
មារមានបាបចាញ់ព្រះអង្គហើយ !

ពោលមួយឃ្លាម្តងៗ អោយថាតាព្រមៗគ្នាបីដង។
ពោលបណ្តើរបាចសាចសុគន្ធបូជាបណ្តើរ។

# ការប្រកាសមាឃបូជា

បពិត្រព្រះដ៏មានព្រះភាគ ថ្ងៃនេះ ជាថ្ងៃពេញបូណ៌មី ១៥កើតខែមាឃ ខ្ញុំព្រះអង្គទាំងឡាយជាកូនចៅព្រះអង្គបានមកជួបជុំគ្នាក្នុងពេលនេះ ដើម្បីធ្វើពិធីរំលឹកដល់បុព្វហេតុពីរប្រការដែលកើតឡើងក្នុងសម័យពុទ្ធកាលៈ

បុព្វហេតុទីមួយ រំលឹកដល់ថ្ងៃដែលព្រះអង្គសំដែងឱវាទបាតិមោក្ខដល់មហាសន្និបាតព្រះសង្ឃដែលជាការប្រជុំប្រកបដោយអង្គបួន គឺថ្ងៃនោះ ជាថ្ងៃពេញបូណ៌មី ១៥កើតខែមាឃ ជាអង្គទី១, ព្រះសង្ឃចំនួន១២៥០អង្គដោយមិនបានណាត់គ្នាជាមុនសោះ ស្រាប់តែមកជួបជុំគ្នានៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ ជាអង្គទី២, ព្រះសង្ឃទាំងអស់ជាឯហិភិក្ខុ គឺបានបួសក្នុងសំណាក់ព្រះពុទ្ធដោយផ្ទាល់ ជាអង្គទី៣, ព្រះសង្ឃទាំងនោះជាព្រះអរហន្តបានសម្រេចអភិញ្ញា ជាអង្គទី៤។

បុព្វហេតុទីពីរ រំលឹកដល់ថ្ងៃដែលព្រះអង្គដាក់ជន្មាយុសង្ខារថា នៅតែ៣ខែទៀតទេ ព្រះអង្គនឹងរំលត់ខន្ធ

បរិនិព្វានហើយ។ ហេតុពីរប្រការនេះ កើតឡើងក្នុងថ្ងៃ១៥កើតខែមាឃដូចគ្នា។

បពិតព្រះពុទ្ធឈ្នះមារ ក្នុងថ្ងៃមាឃបូជានេះ ខ្ញុំព្រះអង្គទាំងឡាយ សូមសំដែងនូវការគោរពដ៏ជ្រាលជ្រៅចំពោះព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងសក្ការៈបូជាទាំងឡាយមានប្រទីបនិងផ្កាជាដើមនេះ និងសូមតាំងចិត្តជាថ្មីនឹងប្រតិបត្តិតាមឱវាទរបស់ព្រះអង្គជានិច្ច ចាប់ពីពេលនេះតទៅហោង។

# ការប្រកាសពិសាខបូជា

បពិតព្រះដ៏មានព្រះភាគ ថ្ងៃនេះ ជាថ្ងៃពេញបូណ៌មី ១៥កើតខែពិសាខ ខ្ញុំព្រះអង្គទាំងឡាយជាកូនចៅព្រះអង្គបានមកជួបជុំគ្នាក្នុងពេលនេះ ដើម្បីរំលឹកដល់ហេតុអស្ចារ្យបីប្រការ ដែលកើតឡើងក្នុងសម័យពុទ្ធកាល គឺថ្ងៃដែលព្រះអង្គប្រសូត ត្រាស់ដឹង និងរំលត់ខន្ធបរិនិព្វាន។ ហេតុបីប្រការនេះ កើតឡើងក្នុងថ្ងៃ១៥កើតខែពិសាខដូចគ្នា។

បពិតព្រះពុទ្ធជាគ្រូនៃមនុស្សនិងទេវតាទាំងឡាយ ពិតមែនតែព្រះអង្គរំលត់ខន្ធបរិនិព្វានបាត់ទៅហើយ ប៉ុន្តែ នៅធម៌វិន័យទុកសំរាប់ឲ្យសត្វប្រតិបត្តិតាមជាក្រោយ។ ក្នុងថ្ងៃពិសាខបូជានេះ ខ្ញុំព្រះអង្គទាំងឡាយ សូមសំដែងនូវ ការគោរពដ៏ខ្ពស់ខ្ពង់ចំពោះព្រះពុទ្ធជាម្ចាស់ ដោយគ្រឿង សក្ការៈបូជា មានប្រទីប និងបុប្ផាជាដើមនេះហើយសូម តាំងចិត្តជាថ្មីនឹងប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះ អង្គ រហូតអវសាននៃជីវិតទៅហោង។

## ការតាំងចិត្តពេលធ្វើកុសល

ឥទំ វត នោ បុញ្ញំ អាសវក្ខយាវហំ ហោតុ

អនាគតេ កាលេ។

រីបុណ្យរបស់យើងខ្ញុំទាំងឡាយនេះ សូមឲ្យបាន ជាបច្ច័យនាំមកនូវធម៌ជាទីអស់ទៅនៃអាសវក្ខិលេស គឺ ព្រះនិព្វាន ឰដ៏អនាគតកាលទៅមុខនោះហោង។

# កំណាព្យ
# សំរាប់សិស្ស និងនិស្សិត
## វគ្គ១
## (បានត្រូវយកទៅធ្វើជាបទចំរៀងបូរាណខ្មែរ)


| | |
|---|---|
| ១. នមស្ការព្រះរតនត្រ័យ | ៤១ |
| ២. បទលើកទង់ព្រះពុទ្ធសាសនា | ៤២ |
| ៣. បទដាក់ទង់ព្រះពុទ្ធសាសនា | ៤២ |
| ៤. ថ្វាយបង្គំព្រះពុទ្ធ | ៤៣ |
| ៥. ធ្វើតាមបណ្ដាំអ្នកមានគុណ | ៤៤ |
| ៦. សាវតារខ្មែរ | ៤៥ |
| ៧. នមស្ការព្រះរតនត្រ័យ | ៤៦ |
| ៨. មាគ៌ាព្រះពុទ្ធសាសនា | ៤៧ |
| ៩. បណ្ដាំម្ដាយ | ៤៨ |
| ១០. អរិយធម៌ខ្មែរ | ៤៨ |
| ១១. សាវតារខ្មែរ | ៤៩ |
| ១២. ជូនពរថ្ងៃកំណើត | ៥០ |

១៣. យុវជននិងយុវតីខ្មែរ ៥០
១៤. នមស្ការព្រះរតនត្រ័យ ៥១
១៥. ការតាំងចិត្តនៅពេលធ្វើទាន ៥២
១៦. ព្រះនាមព្រះពុទ្ធ «ពុទ្ធោ» ៥៣
១៧. នមស្ការព្រះរតនត្រ័យ ៥៤
១៨. ពាក្យខមាទោស ៥៥
១៩. ពាក្យថ្វាយខ្លួន ៥៥
២០. ការតាំងចិត្តពេលធ្វើកុសល ៥៦
២១. អនុមោទនាបុណ្យ ៥៦
២២. ពាក្យរបស់កូនពោលពេលធ្វើបុណ្យ
ជូនឪពុកម្តាយ ៥៧
២៣. ពាក្យឪពុកម្តាយពោលតបទៅកូនវិញ ៥៨
២៤. ព្រលឹងខ្មែរ ៥៩

អត្ថបទទី១

# នមស្ការព្រះរតនត្រ័យ

បទពាក្យ៧

ធ្វើតាមលំនាំបទសរភ័ញ្ញ

យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ឆ្ពោះព្រះបរម ព្រះសម្ពុទ្ធ
ទ្រង់ត្រាស់ដឹងធម៌ ជ្រៅបំផុត ព្រះទ័យបរិសុទ្ធ គុណាករុណា។
បង្គំព្រះធម៌ ផ្លូវប្រតិបត្តិ សំរាប់កំចាត់ កិលេសតណ្ហា
សម្រេចនិព្វាន បានសុខា ឆ្លងវដ្តសង្សារ គ្មានទុក្ខភ័យ។
បង្គំព្រះសង្ឃ តំណាងព្រះពុទ្ធ មានសីលបរិសុទ្ធ កាន់វិន័យ
ទេសនាទូន្មាន ជនប្រុសស្រី ឲ្យយល់អត្ថន័យ ព្រះធម្មា។
ដោយអានុភាព គុណកែវបី សូមសុខសួស្តី ដល់ខេមរា
សូមមានជ័យជោគ រួចទុក្ខា សូមកម្ពុជា បានសុខសាន្ត។

អត្ថបទទី២

# បទលើកទង់ព្រះពុទ្ធសាសនា

បទពាក្យ៨

យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ព្រះពុទ្ធឧត្តម ខ្ពង់ខ្ពស់មានជោគ
ព្រះអង្គជាម្លប់ សត្វក្នុងត្រៃលោក បំបាត់ទុក្ខសោក ដោយព្រះបារមី។
ទង់ជ័យសាសនា តំណាងព្រះអង្គ ពន្លឺផ្សូរផង់ ឆព្វណ្ណរង្សី
កូនចៅគ្រប់ប្រាណ លើកជ្រោងទង់ជ័យ ប្រតិបត្តិឃ្មាតខ្មី
តាមព្រះធម្មា។
សូមព្រះសម្ពុទ្ធ ប្រោសប្រទានពរ ជោគជ័យបវរ ដល់ជនខេមរា
ព្រមទាំងមនុស្សសត្វ នៅក្នុងលោកា ឲ្យបានសុខា តរៀងទៅហោង។

អត្ថបទទី៣

# បទដាក់ទង់ព្រះពុទ្ធសាសនា

បទពាក្យ៧

សូមជ្រកក្រោមទង់ ព្រះបារមី ព្រះពុទ្ធជិនស្រី ឈ្នះលោកា
ព្រះអង្គជាគ្រូ មនុស្សទេព្តា យើងខ្ញុំគ្រប់គ្នា ដើរតាមព្រះអង្គ។
សូមរក្សាទុក ទង់សាសនា គឺព្រះធម្មា ចិត្តស្មោះត្រង់
ប្រតិបត្តិតាមធម៌ ស្អាតផ្សូរផង់ មាគ៌ាដ៏ត្រង់ និព្វានសុខា។
ព្រះពុទ្ធសាសនា គឺព្រលឹងខ្មែរ មានមកហូរហែ ពីដូនតា
ស្ថិតក្នុងដួងចិត្ត ខ្មែរគ្រប់គ្នា ដឹកនាំកម្ពុជា បានសុខសាន្ត។

អត្ថបទទី៤

# ថ្វាយបង្គំព្រះពុទ្ធ

បទពាក្យ៤

យើងខ្ញុំព្រះអង្គ បង្គំវន្ទា
ព្រះពុទ្ធឈ្នះមារ គ្រូមនុស្សទេព្តា។
ព្រះអង្គជាម្លប់ បង្ហាញធម្មា
ឲ្យរួចទុក្ខា ដាក់ដល់និព្វាន។
ពួកសត្វអស់ទុក្ខ បានសុខក្សេមក្សាន្ត
យើងខ្ញុំគ្រប់ប្រាណ យកជាទីពឹង។

អត្ថបទទី៥

# ធ្វើតាមបណ្ដាំអ្នកមានគុណ

បទពាក្យ៨

ព្រះមេទាំងពីរ មានគុណដ៏ធ្ងន់ កូនសូមបន្ទន់ កាយាគោរព
មាតាបិតា ទាំងពីរជាម្លប់ សូមម្ដាយឪពុក សុខភាពរឹងមាំ។
ម៉ែចិញ្ចឹមកូន ដោយចិត្តករុណា លំបាកយ៉ាងណា ក៏ម៉ែស៊ូទ្រាំ
លាងម៉ូត្រលាមក បីពថៃទាំ មានគុណដ៏ធ្ងន់ ធ្ងន់ខ្លាំងអស្ចារ្យ។
ភ្នំព្រះសុមេរុ៍ សែនធ្ងន់បំផុត ជម្រៅសមុទ្រ មិនអាចឧបមា
គុណលោកទាំងពីរ ដែលមានព្រហ្មវិហារ មេត្តាករុណា
ដល់កូនស្រីប្រុស។
យើងខ្ញុំជាកូន ធ្វើតាមបណ្ដាំ ពាក្យលោកបានផ្ដាំ មិនធ្វើឲ្យខុស
ខំប្រតិបត្តិតាម រក្សាកេរ្ដិ៍ឈ្មោះ ពូជពង្សដ៏ខ្ពស់ នៃជនខេមរា។

អត្ថបទទី៦

# សាច់តារខ្មែរ

បទកាកគតិ

ពង្សសាវតារខ្មែរ ចារមកហូរហែ កម្ពុជាបូរី
មានអារ្យធម៌ ខ្ពង់ខ្ពស់ប្រពៃ សុសសាយព្ទល្បី
សម័យអង្គរ។
ដីខ្មែរធំធេង លាតសន្ធឹងវែង សម្រស់បវរ
សម្បត្តិធម្មជាតិ មានទៀតមិនក្រ ខេមរាត្រេកអរ
បេត្តិកភណ្ឌជាតិ។
សូមខ្មែរប្រុសស្រី សាមគ្គីជាថ្មី កុំបីរវាត
នាំគ្នាគិតគូរ ក្នុងប្រយោជន៍ជាតិ តាមព្រះឱវាទ
ព្រះពុទ្ធជិនស្រី។
បងប្អូនខេមរា រស់នៅទីណា សូមសុខសួស្ដី
ជួបជុំគ្រួសារ ញាតិកាប្រុសស្រី សាងកម្ពុជាថ្មី
បានសុខក្សេមក្សាន្ត។

អត្ថបទទី៧

# នមស្ការព្រះរតនត្រ័យ

បទកាកគតិ

សូមថ្វាយបង្គំ ឆ្ពោះព្រះបរម អង្គព្រះសម្ពុទ្ធ
មានបញ្ញាញាណ ភ្លឺថ្លាមុះមុត ព្រះទ័យបរិសុទ្ធ
អាណិតសព្វសត្វ។
បង្គំព្រះធម៌ ឧត្តមបវរ ជ្រាលជ្រៅបរមត្ថ
អង្គមគ្គ៨ សំរាប់ប្រតិបត្តិ ដើម្បីកាត់ផ្តាច់
ពីវដ្តសង្សារ។
បង្គំព្រះសង្ឃ ប្រសើរសីលទ្រង់ បរិសុទ្ធថ្លៃថ្លា
ទុកជាតំណាង ព្រះបរមសាស្តា បន្តសាសនា
នៃព្រះជិនស្រី។
ដោយអានុភាព នៃការក្រួញក្រាប ព្រះរតនត្រ័យ
ដោយចិត្តជ្រះថ្លា គុណកែវទាំងបី សូមផុតទុក្ខភ័យ
ដល់និព្វានហោង។

អត្ថបទទី៨

# មាគ៌ាព្រះពុទ្ធសាសនា

បទពាក្យ៨

ព្រះធម៌ជាច្បាប់ ដែលព្រះពុទ្ធជាម្ចាស់
បានត្រាស់ដឹងច្បាស់ ជាផ្លូវបរិសុទ្ធ
ដឹកនាំមនុស្សសត្វ ឲ្យចេញចាកទុក្ខ
ប្រសើរបំផុត លើសអស់មាគ៌ា។
ធម៌អហឹង្សា ការស្ងប់ផ្លូវចិត្ត
មិនមានគំនិត ធ្វើបាបនានា
នេះជាឱវាទ ព្រះពុទ្ធឈ្នះមារ
សត្វបានសុខា ដោយចិត្តស្អាតល្អ។
ខ្មែរជ្រកម្លប់ពោធិ៍ គឺពុទ្ធសាសនា
បានរួចទុក្ខា ដោយម្លប់ព្រះធម៌
ពាក្យថាធម្មិក ប្រែថាមនុស្សល្អ
ជាអ្នកមានធម៌ ស្ថិតនៅក្នុងខ្លួន។

អត្ថបទទី៩

# បណ្ដាំម្ដាយ

បទពាក្យ៧

ឱកូនពន្លក បុត្រមាសម្ដាយ ចូរកូនមកអាយ ម្ដាយផ្ដាំបា
ព្រលឹងខ្មែរយើង គឺពុទ្ធសាសនា មានមកយូរយាក្នុងឈាមខេមរា។
ព្រះធម៌ព្រះពុទ្ធ មានតម្លៃ ចូរកូនមាសថ្លៃ ត្រូវរក្សា
ប្រតិបត្តិតាម ជាមាគ៌ា របស់កម្ពុជា អនុវត្តគ្រប់ប្រាណ។
ពុទ្ធសាសនិកខ្មែរ កាន់ធម្មា គ្មានកម្លាំងណា បំបែកបាន
ស្ថិតក្នុងដួងចិត្ត ខ្មែរគ្រប់ប្រាណ បានសុខក្សេមក្សាន្ត
ចូរកូនចងចាំ។

អត្ថបទទី១០

# អរិយធម៌ខ្មែរ

បទពាក្យ៧

ជាតិខ្មែរមានឈាម ដ៏ថ្លៃថ្នូរ តពូជអម្បូរ ពីដូនតា
មានអារ្យធម៌ ខ្ពស់អស្ចារ្យ នៅចុងបូព៌ា សម័យអង្គរ។
នេះដោយដើរតាម ធម៌ព្រះពុទ្ធ មាគ៌ាបរិសុទ្ធ ថ្លៃបវរ
គឺជាមូលដ្ឋាន នៃវប្បធម៌ សម្បត្តិដ៏ល្អ នៃកម្ពុជា។
សង្គមធម៌ខ្មែរ ក៏រុងរឿង ជីវភាពចុំច្រើង តាមសាវតារ
សូមខ្មែរគ្រប់រូប សាងកម្ពុជា ឲ្យមានវឌ្ឍនា ដូចដើមវិញ។

អត្ថបទទី១១

# សាចតារខ្មែរ

ខ្មែរអើយចូរចងចាំថា តាមសាវតារ ជាតិខេមរា ពូជពណ្ណរាយ ជាមហាអំណាច អង់អាចល្បីល្បាញ កាលពីព្រេងនាយ មានទឹកដីធំទូលាយ ល្បីឈ្មោះសុសសាយ ទិសទាំងឡាយទ្វីបអាស៊ី។

ក្នុងសម័យមហានគរ ថ្កុំថ្កើងបវរ ដើរតាមព្រះធម៌ ព្រហ្មវិហារ មេត្តាករុណា ព្រះធម៌ព្រះពុទ្ធ ខ្មែររាប់អានគ្នា មានសាមគ្គីសាមគ្គា ធម៌ព្រហ្មវិហារ ទឹកបន្សាបរួបរួមខ្មែរ។

ខ្មែរអើយចូរចាំសាវតារ ដែលបានចែងចារ បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង នាំគ្នាប្រឹងប្រែង រក្សាអារ្យធម៌ ឲ្យរីកវិញឡើង និងលើកតម្កើង សីលធម៌ជាតិយើង ឲ្យថ្កុំថ្កើងតាមសាវតារ។

អត្ថបទទី១២

## ជូនពរថ្ងៃកំណើត

បទពាក្យ៧

សូមជូនពុទ្ធពរ ៤ប្រការ ដោយរាប់អានគ្នា ដ៏ស្មោះស្ម័គ្រ
ក្នុងថ្ងៃកំណើត របស់អ្នក ជួបជុំមិត្តភ័ក្ត្រ ស្និទ្ធមេត្រី។
អាយុ វណ្ណៈ សុខៈ ពលៈ សូមមានដល់អ្នក រួចទុក្ខភ័យ
ជួបជុំគ្រួសារ ញាតិប្រុសស្រី បានសុខសួស្តី តទៅអើយ។

អត្ថបទទី១៣

## យុវជននិងយុវតីខ្មែរ

បទពាក្យ៨

យើងជាយុវជន និងយុវតី កូនខ្មែរប្រុសស្រី អ្នកពុទ្ធសាសនា
ដើរតាមព្រះពុទ្ធ ធ្វើតាមធម្មា បានក្លាយទៅជា កូនចៅខ្មែរល្អ។
គោរពមាតា និងព្រះបិតា ចាស់ព្រឹទ្ធាចារ្យ អ្នកមានសីលធម៌
លះបង់អបាយមុខ តែងតែធ្វើល្អ ធ្វើតាមព្រះធម៌ ពាក្យពុទ្ធដីកា។
ចរិយាសម្បត្តិ ជាផ្នែកគុណធម៌ វិជ្ជាបវរ ជាផ្នែកបញ្ញា
រួមផ្នែកទាំងពីរ ទើបពេញលក្ខណា ជាមនុស្សថ្លៃថ្លា
នៅក្នុងសង្គម។

អត្ថបទទី១៤

# នមស្ការព្រះរតនត្រ័យ

បទពាក្យ៨

យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ឆ្ពោះព្រះបរម អង្គព្រះសម្ពុទ្ធ
ទ្រង់ត្រាស់ដឹងធម៌ ជ្រាលជ្រៅបំផុត ដឹកនាំសព្វសត្វ
ឆ្លងកាត់ទុក្ខា។
បង្គំព្រះធម៌ ជាឱសថទិព្វ សត្វណាបានផឹក រួចវដ្តសង្សារ
ជាទឹកអម្រឹត គឺធម៌ពិតថ្លា ផ្លូវមជ្ឈិមា សំរាប់ប្រតិបត្តិ។
បង្គំព្រះសង្ឃ តំណាងព្រះពុទ្ធ មានសីលបរិសុទ្ធ ឥតមានវិបត្តិ
ទុកជាស្រែបុណ្យ នៃពុទ្ធបរិស័ទ សំរាប់កម្ចាត់ កិលេសតណ្ហា។
ដោយអានុភាព គុណកែវទាំងបី សូមសុខសួស្តី ដល់ជនខេមរា
សូមមានជ័យជោគ រួចពីទុក្ខា សូមពុទ្ធសាសនា
ខ្មែរបានរុងរឿង។

អត្ថបទទី១៥

# ការតាំងចិត្តនៅពេលធ្វើទាន

បទពាក្យ៧

ទាននៃយើងខ្ញុំ ទាំងអស់គ្នា ដែលបានបូជា បរិសុទ្ធល្អ
ដោយចិត្តជ្រះថ្លា ត្រង់ស្មោះសរ រីករាយត្រេកអរ ឥតថ្នាំងថ្នាក់។
ដោយតេជះផល អានិសង្ស មកជួយស្រោចស្រង់ កុំបីអាក់
នាំចេញឲ្យអស់ នូវអាសវៈ ជាគ្រឿងជំពាក់ ក្នុងសន្ដាន។
យើងខ្ញុំឧទ្ទិស កុសលបុណ្យ ដល់អ្នកមានគុណ ដែលចែកស្ថាន
ព្រមទាំងញាតិមិត្ត ទាំងប៉ុន្មាន សូមទទួលបាន ផលបុណ្យនេះ។

អត្ថបទទី១៦

# ព្រះនាមព្រះពុទ្ធ «ពុទ្ធោ»

បទពាក្យ៨

ពាក្យថាពុទ្ធោ ព្រះនាមព្រះពុទ្ធ   បញ្ញាមុះមុត ការត្រាស់ដឹងធម៌
គឺអរិយសច្ច៤ ប្រសើរបវរ   ទើបមាននាមធម៌ ព្រះពុទ្ធឈ្នះមារ។
សច្ចៈទី១ គឺសេចក្តីទុក្ខ   សត្វមិនបានសុខ ក្នុងវដ្តសង្សារ
ព្រោះមានខន្ធ៥ ជាតួទុក្ខា   គប្បីពិចារណា ធ្វើទុកក្នុងចិត្ត។
សច្ចៈទី២ ហេតុនាំឲ្យទុក្ខ   តណ្ហាដឹកមុខ នាំឲ្យភ័យភិត
វិលកើតវិលស្លាប់ ក្នុងសង្សារពិត   ធម៌នេះកំរិត ឲ្យលះប្រហារ។
សច្ចៈទី៣ គឺនិរោធសច្ច   តណ្ហាលះផ្តាច់ និព្វានសុខា
ដើរតាមមគ្គ៨ ត្រូវបួនប្រការ   របស់អរិយា ផ្លូវរំដោះទុក្ខ។

អត្ថបទទី១៧

# នមស្ការព្រះរតនត្រ័យ

បទព្រហ្មគីតិ

សូមផ្គងអញ្ជលី ឆ្ពោះព្រះមុនីសាស្តាចារ្យ
ជាគ្រូមនុស្សទេព្តា ទាំងព្រហ្មាក្នុងភពបី។
មានញាណថ្លាមុះមុត ស្អាតបរិសុទ្ធក្នុងព្រះទ័យ
ប្រោសសត្វក្នុងលោកីយ៍ ឆ្លងភពបីដោយទេសនា។
បង្ហាញនូវធម្មា សីលសមាធិបញ្ញា
ទុកដូចជានាវា នាំសត្តាដល់និព្វាន។
ព្រះសង្ឃអង្គពិសេស ស្ងប់កិលេសក្នុងសន្តាន
សាវកព្រះទ្រង់ញាណ គង់ធរមាន តសាសនា។
ដោយគុណរតនត្រៃ កែវទាំងបីថ្វាយវន្ទា
សូមសម្រេចផល្លា រួចទុក្ខា និព្វានហោង។

អត្ថបទទី១៨

# ពាក្យខមាទោស

បទពាក្យ៤

បពិត្រព្រះសង្ឃ ទោសកំហុសណា
ដែលខ្ញុំព្រះករុណា ធ្វើកន្លងទៅ។
ដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ
មិនគោរពឆ្ពោះទៅ ព្រះត្រៃរតនា។
បពិត្រព្រះសង្ឃ សូមអត់ទោសា
ដល់ខ្ញុំព្រះករុណា នឹងសង្គ្រួមតទៅ។

អត្ថបទទី១៩

# ពាក្យថ្វាយខ្លួន

បទពាក្យ៤

ខ្ញុំព្រះករុណា សូមយកព្រះពុទ្ធ
ដែលនិព្វានផុត ទីពឹងអាស្រ័យ។
ព្រះធម៌ព្រះសង្ឃ ជាប់ជានិស្ស័យ
បានជាបច្ច័យ និព្វានសុខា។
ជាឧបាសក ឧបាសិកា
ឆ្ពោះត្រៃរតនា ស្មើដោយជីវិត។

អត្ថបទទី២០

# ការតាំងចិត្តពេលធ្វើកុសល

បទពាក្យ៤

បុណ្យខ្ញុំធ្វើហើយ សូមឲ្យអស់ទៅ
កុំឲ្យសល់នៅ អាសវៈតណ្ហា។
ដើម្បីនិព្វាន រួចពីទុក្ខា
ឆ្លងវដ្តសង្សារ ជាបរមសុខពិត។
កុសលគ្រប់យ៉ាង ដុសខាត់ផ្លូវចិត្ត
ឲ្យស្អាតប្រណីត ទើបរួចទុក្ខា។

អត្ថបទទី២១

# អនុមោទនាបុណ្យ

បទពាក្យ៤

យើងខ្ញុំប្រុសស្រី សូមអនុមោទនា
កុសលផល្លា ដោយចិត្តស្មោះសរ។
សាធុសាធុ ទទួលត្រេកអរ
ដោយក្តីអំណរ ជ្រះថ្លាក្នុងចិត្ត។
បុណ្យឆ្លងពីទុក្ខ បានក្តីសុខពិត
ពីភពងងឹត ដល់និព្វានហោង។

អត្ថបទទី២២

# ពាក្យរបស់កូនពោល
# ពេលធ្វើបុណ្យជូនឪពុកម្ដាយ

បទពាក្យ៤

បពិត្រពុកម៉ែ អ្នកមានគុណធ្ងន់
គុណមានទម្ងន់ លើកូនប្រុសស្រី។
សូមអ្នកមានគុណ អនុគ្រោះប្រណី
អត់នូវទោសពៃរ៍ នូវកំហុសកូន។
បុណ្យកុសលនេះ កូនសូមលើកជូន
ផលបុណ្យជាក្បូន ជូនលោកផុតទុក្ខ។
ជីវិតបច្ចុប្បន្ន សូមលោកបានសុខ
ព្រះជន្មទៅមុខ ជាម្លប់ដល់កូន។

អត្ថបទទី២៣

# ពាក្យឪពុកម្ដាយ
# ពោលតបទៅកូនវិញ

បទពាក្យ៤

ឱកូនពិសី ពុកម៉ែអត់ទោស
ដោយក្ដីអនុគ្រោះ អោយកូនគ្រប់គ្នា។
ពុកម៉ែទទួលបុណ្យ កតញ្ញូតា
ដែលកូនជ្រះថ្លា លើកជូនពេលនេះ។
ការងារដោយធម៌ ស្វែងរកចំណេះ
រៀនអោយបានចេះ ផ្លូវលោកផ្លូវធម៌។
នេះជាបណ្ដាំ ដល់កូនបវរ
គប្បីត្រេកអរ យកទៅអនុវត្ត។

អត្ថបទទី២៤

# ព្រលឹងខ្មែរ

បទពាក្យ៧

កម្ពុជាជាដួង ព្រលឹងខ្ញុំ ធ្លាប់មានមនោរម្យ ពីបុរាណ
មានអារ្យធម៌ រុងរឿងថ្កាន ជាទីសុខសាន្ត មកហូរហែ។
បងប្អូនជាតិខ្មែរ នៅទីណា គប្បីគិតថា យើងជាខ្មែរ
នាំគ្នាប្រឹងប្រែង រក្សាថៃ ព្រលឹងជាតិខ្មែរ ពីដូនតា។
កាន់ធម៌សាមគ្គី រួបរួមគ្នា ស្របតាមមាគ៌ា ពុទ្ធសាសនា
សុខពីការស្ងប់ ក្នុងចិន្តា វប្បធម៌ខេមរា ព្រលឹងជាតិយើង។

# កំណាព្យ
# សំរាប់សិស្ស និងនិស្សិត
## វគ្គ២
**(បានត្រូវយកទៅធ្វើជាបទចំរៀងបុរាណខ្មែរ)**


| | |
|---|---|
| ០១. កុំសេពថ្នាំយ៉ាម៉ាយ៉ាបាយ៉ាអ៊ី | ៦១ |
| ០២. ភារកិច្ចកូនចៅក្នុងបឋមវ័យ | ៦២ |
| ០៣. ក្រមសីលធម៌របស់កូនប្រុសស្រី | ៦៣ |
| ០៤. តម្លៃនៃវិជ្ជា | ៦៤ |
| ០៥. ត្រូវមានអនាម័យដើម្បីសុខភាព | ៦៥ |
| ០៦. សុជីវធម៌សម្រាប់កូនប្រុសស្រី | ៦៦ |
| ០៧. ពេលកូននៅផ្ទះ | ៦៧ |
| ០៨. សីល៥ ជាពូជមនុស្ស | ៦៨ |
| ០៩. ជូនពរមាតាបិតា | ៦៩ |
| ១០. ក្បួនរៀនឆាប់ចេះ | ៧០ |
| ១១. ធម៌នាំឲ្យសម្រេចកិច្ចការ | ៧១ |
| ១២. ត្រូវតស៊ូក្នុងការសិក្សា | ៧២ |

១៣. ត្រូវរក្សាវប្បធម៌ខ្មែរ ៧៣
១៤. ឈ្លក់នឹងស្នេហានាំខ្លីវិជ្ជា ៧៤
១៥. សិទ្ធិមនុស្សក្នុងព្រះពុទ្ធសាសនា ៧៥

## អត្ថបទទី១

# កុំសេពថ្នាំយ៉ាម៉ាយ៉ាបាយ៉ាអុី

## បទពាក្យ៧

ឱកូនមាសម្ដាយ ថ្លៃស្មើជីវិត    កូនត្រូវតែគិត ពិចារណា
កុំសេពគ្រឿងញៀន ថ្នាំយ៉ាម៉ា   ទាំងថ្នាំយ៉ាបា ថ្នាំយ៉ាអុី។
ថ្នាំទាំងអស់នេះ កុំសាកល្បង   នាំឲ្យសៅហ្មង រោគយាយី
នាំខូចសុខភាព ជាតិគីមី        បុរសនារី ជៀសឲ្យឆ្ងាយ។
ថ្នាំនេះខុសច្បាប់ រដ្ឋបានហាម  បើមិនធ្វើតាម នាំអន្តរាយ
ត្រូវរដ្ឋដាក់ទោស ដល់រូបកាយ  មិនគិតវែងឆ្ងាយ
អន្តរាយជីវិត។
សុខតែមួយភ្លាត ទុក្ខយឺនយូរ   ចូរកូនកុំប្អូរ កុំប្រព្រឹត្ត
ខុសទាំងច្បាប់រដ្ឋ ខូចទាំងជីវិត   មិនត្រូវទៅជិត
ប្រព្រឹត្តវាឡើយ។

អត្ថបទទី២

# ភារកិច្ចកូនចៅក្នុងបឋមវ័យ

បទពាក្យ៤

កូនចៅកម្ពុជា ក្នុងបឋមវ័យ
ភារកិច្ចប្រពៃ គឺការសិក្សា។
វិជ្ជាផ្លូវលោក អប់រំចរិយា
កើតមានបញ្ញា ចរិយាប្រពៃ។
នៅក្នុងសាលា គោរពវិន័យ
កូនមានជោគជ័យ ក្នុងការសិក្សា។
យកចិត្តទុកដាក់ បំពេញកិច្ចការ
គ្រូសាស្ត្រាចារ្យ ដាក់ឲ្យកូនធ្វើ។

អត្ថបទទី៣

# ក្រមសីលធម៌របស់កូនប្រុសស្រី

## បទពាក្យ៤

ល្បែងស្រីល្បែងស្រា និងល្បែងស៊ីសង
ជាល្បែងខុសឆ្គង កូនជៀសគ្រប់គ្នា។
កុំជក់គ្រឿងញៀន អាភៀនកញ្ឆា
អំពើហឹង្សា កូនជៀសឲ្យឆ្ងាយ។
កុំសេពគប់ពាល នាំឲ្យអន្តរាយ
ត្រូវស្តាប់ពាក្យម្តាយ គ្រូសាស្ត្រាចារ្យ។
នេះក្រមសីលធម៌ នាំកូនគ្រប់គ្នា
ឲ្យបានសុខា ផុតទោសក្នុងលោក។

អត្ថបទទី៤

# តម្លៃនៃវិជ្ជា

## បទពាក្យ៤

វិជ្ជាជាទ្រព្យ ដ៏មានតម្លៃ
ចូរកូនប្រុសស្រី ស្វែងរកឲ្យបាន។
ជាទ្រព្យមរតក ស្ថិតក្នុងខ្លួនប្រាណ
ចោរលួចមិនបាន កើតមានទ្រព្យធារ។
ពន្លឺវិជ្ជា អាចដោះបញ្ហា
ជ្រាលជ្រៅយ៉ាងណា នៅក្នុងជីវិត។
ពន្លឺព្រះចន្ទ ភ្លឺយប់ងងឹត
ថ្ងៃព្រះអាទិត្យ វិជ្ជាភ្លឺសព្វ។

អត្ថបទទី៥

# ត្រូវមានអនាម័យដើម្បីសុខភាព

បទពាក្យ៤

កាយមានសុខភាព ជាលាភនៃមនុស្ស
កូនចៅស្រីប្រុស ត្រូវថែរក្សា។
សំអាតខ្លួនប្រាណ ជៀសវាងរោគា
ក្រោយធ្វើការងារ លាងដៃឲ្យស្អាត។
នៅជុំវិញផ្ទះ ត្រូវបោសសំអាត
បរិភោគតាមខ្នាត ឲ្យទៀងរាល់ថ្ងៃ។
កុំឲ្យមានរោគ ត្រូវមានអនាម័យ
មេរោគចង្រៃ បៀតបៀនមិនបាន។

## អត្ថបទទី៦

# សុជីវធម៌សម្រាប់កូនប្រុសស្រី

## បទពាក្យ៤

សុជីវធម៌ រស់នៅសមរម្យ
ស្របតាមសង្គម កូនចៅកម្ពុជា។
គប្បីគោរព មាតាបិតា
គ្រូសាស្ត្រាចារ្យ លោកផ្តល់វិជ្ជា។
បង្គំព្រះសង្ឃ ប្រទានធម្មា
ចាស់មានសីលា មានធម៌សន្តោស។
បើកូនខុសឆ្គង ត្រូវតែសុំទោស
បើគេធ្វើខុស កូនគួរអត់ឱន។

## អត្ថបទទី៧

# ពេលកូននៅផ្ទះ

## បទពាក្យ៤

កូនចេញពីរៀន រួតរះមកផ្ទះ
មិនត្រូវគេចវេះ ទៅទីនានា។
ត្រូវជួយការងារ មាតាបិតា
ដោយគារវតា កិច្ចការក្នុងផ្ទះ។
ពេលទៅសាលា លើកដៃសំពះ
ត្រឡប់មករួតរះ ក៏គោរពដូចគ្នា។
មានបញ្ហាអ្វី មិនត្រូវលាក់ការ
ត្រូវប្រាប់មាតា បិតាដោះស្រាយ។

អត្ថបទទី៨

# សីល៥ជាពូជមនុស្ស

បទពាក្យ៤

សីល៥ជាពូជ ធម៌មនុស្សគ្រប់វ័យ
ក្មេងចាស់ប្រុសស្រី គប្បីប្រតិបត្តិ។
មិនត្រូវសម្លាប់ ជីវិតមនុស្សសត្វ
មិនលួចសម្បត្តិ ទ្រព្យអ្នកដទៃ។
មិនលួចប្រពន្ធ កូនស្រីនិងប្តី
ជាសីលទីបី បួនពោលពាក្យពិត។
គ្រឿងស្រវឹងគ្រឿងញៀន មិនត្រូវប្រព្រឹត្ត
នេះធម៌សុចរិត ពូជពង្សមនុស្សធម៌។

អត្ថបទទី៩

# ជូនពរមាតាបិតា

## បទពាក្យ៤

កូនសូមជូនពរ មាតាបិតា
សូមមានជន្មា ជីវិតយឺនយូរ។
មានសុខភាពល្អ កម្លាំងបរិបូរណ៍
ព្រះជន្មយឺនយូរ បានកូនតបគុណ។
ដោយអានុភាព កុសលផលបុណ្យ
ដែលអ្នកមានគុណ បានបំពេញហើយ។
សូមឆាប់សម្រេច ជូនលោកដល់ត្រើយ
ផុតទុក្ខបានស្បើយ ដល់និព្វានហោង។

អត្ថបទទី១០

# **ក្បួនរៀនឆាប់ចេះ**

បទពាក្យ៤

អង្គ៤ប្រការ ទីមួយប្រុងស្តាប់
គ្រូពន្យល់ប្រាប់ តាមមុខវិជ្ជា។
ទីពីរខំគិត ធ្វើមនសិការ
មិនយល់ត្រង់ណា សាកសួរទីបី។
ទីបួនកត់ទុក នូវពាក្យសំដី
ថ្ងៃក្រោយភ្លេចន័យ អាចមើលបញ្ជាក់។
នេះក្បួនសិក្សា ចូរសិស្សគ្រប់ថ្នាក់
អនុវត្តពិតជាក់ ក្បួនរៀនឆាប់ចេះ។

អត្ថបទទី១១

# ធម៌នាំឲ្យសម្រេចកិច្ចការ

## បទពាក្យ៤

ឥទ្ធិបាទ៤ ទីមួយឆន្ទៈ
បំណងជាក់លាក់ ទៅលើកិច្ចការ។
ទីពីរវិរិយៈ អនុវត្តផែនការ
ចិត្តៈប្តេជ្ញា តាំងមាំក្នុងចិត្ត។
បួនវិមំសា ពិចារណារិះគិត
គ្រួតការប្រព្រឹត្ត ត្រូវតាមមាគ៌ា។
នេះឥទ្ធិបាទ មាន៤មាត្រា
នាំឲ្យកិច្ចការ អ្វីមួយសម្រេច។

អត្ថបទទី១២

# ត្រូវតស៊ូក្នុងការសិក្សា

បទពាក្យ៤

បើខ្ញុំប្រឡង មិនបានជោគជ័យ
តាំងចិត្តជាថ្មី បន្តសិក្សា។
បើការព្យាយាម ឲ្យបានខ្លាំងក្លា
ខ្ញុំជឿជាក់ថា ប្រឡងនឹងជាប់។
ព្រេងនិងប្រឹង ជាដៃគូរគាប់
ខំប្រឹងមានភ័ព្វ បានជោគជយា។
មិនអស់សង្ឃឹម រត់ចោលសាលា
កូនចៅខេមរា ត្រូវតែតស៊ូ។

អត្ថបទទី១៣

# ត្រូវរក្សាវប្បធម៌ខ្មែរ

## បទពាក្យ៤

លក្ខណៈពិសេស នៃវប្បធម៌ខ្មែរ
មានមកតាំងតែ ព្រេងនាយដូនតា។
សាសនាអក្សរសាស្រ្ត សិល្បៈរចនា
ប្រពៃណីថ្លៃថ្លា ជឿនលឿនប្រពៃ។
នាំគ្នាទប់ទល់ វប្បធម៌ដទៃ
ជំនឿអប្រិយ៍ ចូលមកកម្ពុជា។
ភ្លៀងធ្លាក់សន្ទូងលាស់ ត្រូវថែទាំវា
ស្មៅដុះម្ទីម្នា នាំគ្នាកាត់ចោល។

អត្ថបទទី១៤

# ឈ្លក់នឹងស្នេហានាំខ្លីវិជ្ជា

បទពាក្យ៤

សិស្សនិងនិស្សិត ដែលកំពុងសិក្សា
បើឈ្លក់ស្នេហា នាំខ្លីវិជ្ជា។
បើអាចរៀនបាន ក៏មានបញ្ហា
ព្រោះរវល់ស្នេហា ខ្វះពេលវេលា។
អាទិភាពទីមួយ ត្រូវស្វែងវិជ្ជា
ស្វាមីភរិយា គួរទុកពេលក្រោយ។
ឲ្យកាមដឹកមុខ នាំឲ្យថ្លោះធ្លោយ
កាលណាបណ្ដោយ ខូចការសិក្សា។

អត្ថបទទី១៥

# សិទ្ធិមនុស្សក្នុងព្រះពុទ្ធសាសនា

បទពាក្យ៤

ធម៌អហឹង្សា ការមិនបៀតបៀន
ព្រះពុទ្ធបង្រៀន ដល់មនុស្សស្រីប្រុស។
ជាធម៌គោរព សិទ្ធិនៃមនុស្ស
បានសុខខ្ពង់ខ្ពស់ សង្គមលោកីយ៍។
មិនបៀតបៀនគ្នា ជាសុខប្រពៃ
សង្គមគ្មានភ័យ ដោយគោរពសិទ្ធិគ្នា។
អង្គការពិភពលោក យកធម៌អហឹង្សា
របស់ពុទ្ធសាសនា ជាគោលសិទ្ធិមនុស្ស។

# កំណាព្យ
# សំរាប់សិស្ស និងនិស្សិត
## វគ្គ៣
**(បានត្រូវយកទៅធ្វើជាបទចំរៀងបូរាណខ្មែរ)**

០១. សិទ្ធិកុមារ ៧៧
០២. ការជួញដូរមនុស្ស ៧៩
០៣. ទេសចររួមភេទ ៨០
០៤. ប្រុសចាស់ដើរទិញស្រីក្មេង ៨១
០៥. កុមារខ្មែរបំរើតាមផ្ទះ ៨២
០៦. អ្នកចំណាកស្រុក ៨៣
០៧. ជីវិតអ្នកក្រ ៨៤
០៨. កុមារពិការ ៨៥
០៩. អ្នកកើតរោគអេដ ៨៦
១០. ហឹង្សាក្នុងគ្រួសារ ៨៧
១១. ក្មេងទំនើង ៨៩
១២. បុណ្យចូលឆ្នាំខ្មែរ ៩០

១៣. បុណ្យភ្ជុំបិណ្ឌ ៩២
១៤. បុណ្យកឋិនទាន ៩៣
១៥. បុណ្យពិសាខបូជា ៩៤
១៦. បុណ្យមាឃបូជា ៩៥
១៧. បុណ្យចូលវស្សា ៩៦
១៨. បុណ្យចំរើនព្រះជន្ម ៩៧
១៩. បុណ្យទក្ខិណានុប្បទាន ៩៨

អត្ថបទទី១

# **សិទ្ធិកុមារ**

បទពាក្យ៧

អនុសញ្ញាសិទ្ធិកុមារ
ជាច្បាប់អង្គការសហប្រជាជាតិ
អំពាវនាវឲ្យមនុស្សគ្រប់ជនជាតិ
គោរពកុំឃ្លាតសិទ្ធិកុមារ។
កុមារមានសិទ្ធិត្រូវអប់រំ
ស្របតាមសង្គមជាតិនានា
ដូចជាកុមារជាតិខេមរា
អប់រំចរិយាផ្តល់វិជ្ជា។
ផ្នែកសុខភាពត្រូវថែទាំ
ឲ្យកាយរឹងមាំគ្មានរោគា

រំលោភផ្លូវភេទបង្ខំការងារ
ខុសច្បាប់មាត្រាសិទ្ធិកុមារ។
ត្រូវទុកកុមារដូចជាកូន
ឬដូចបងប្អូនត្រូវការពារ
ស្រឡាញ់ដូចកូននិងមាតា
ទើបសិទ្ធិ៍កុមារត្រូវគេគោរព។

អត្ថបទទី២

# ការជួញដូរមនុស្ស

## បទពាក្យ៤

របរទុច្ចរិត ការជួញដូរមនុស្ស
ជាជំនួញខុស ប្រាសចាកធម្មា។
បោកយកទៅលក់ ធ្វើស្រីពេស្យា
បង្ខំធ្វើការ កន្លែងមានទុក្ខ។
បោករកការងារ ក្នុងស្រុកក្រៅស្រុក
ច្បាប់បានចាត់ទុក អំពើឧក្រិដ្ឋ។
ខ្មែរខ្លះបានធ្វើ ត្រូវឈប់ប្រព្រឹត្ត
គួរតែអាណិត ដល់ជនជាតិខ្លួន។

អត្ថបទទី៣

# ទេសចររួមភេទ

បទពាក្យ៤

ទេសចរមួយភាគ ចូលមកកម្ពុជា
បំណងពួកវា រួមភេទកុមារ។
សូមប្រុងប្រយ័ត្ន មាតាបិតា
កុំចាញ់បោកវា នាំកូនខូចកាយ។
បោករកការងារ រៀបការក្លែងក្លាយ
ឬឲ្យប្រាក់ចាយ ឬសុំជាកូន។
កុំជឿមេខ្យល់ សូម្បីបងប្អូន
បោកបានបញ្ជូន លក់ឲ្យបរទេស។

អត្ថបទទី៤

# ប្រុសចាស់ដើរទិញស្រីក្មេង

## បទពាក្យ៤

ប្រុសចាស់ខ្មែរខ្លះ ក្នុងស្រុកក្រៅស្រុក
បរទេសលាក់មុខ ដើរទិញក្មេងស្រី។
យកមករួមភេទ គ្មានអៀនខ្មាស់អ្វី
អ្នកធំអប្រិយ៍ អាងប្រាក់ដុល្លា។
ក្មេងស្រីរងគ្រោះ ត្រូវអំពើហឹង្សា
ពីនាងភរិយា អ្នកធំព្យាបាទ។
ប្រើទឹកអាស៊ីដ របួសខូចខាត
រាងកាយស្អាតបាត ទៅជាពិការ។

អត្ថបទទី៥

# **កុមារខ្មែរបំរើតាមផ្ទះ**

បទពាក្យ៤

កុមារីខ្មែរ បំរើតាមផ្ទះ
ដូចខ្ញុំកញ្ជះ មិនឲ្យសិក្សា។
អំពើខុសច្បាប់ ពលកម្មកុមារ
បំរើការងារ ក្មេងមិនគ្រប់វ័យ។
ខ្លះរំលោភផ្លូវភេទ គ្មានរៀនខ្មាសអ្វី
អំពើព្រៃផ្សៃ ខុសច្បាប់មាត្រា។
អ្នកកេងប្រវញ្ចន៍ ពលកម្មកុមារ
ខ្លះប្រើហឹង្សា ជាអំពើខុសច្បាប់។

អត្ថបទទី៦

## **អ្នកចំណាកស្រុក**

បទពាក្យ៤

បងប្អូនប្រុសស្រី គប្បីពិចារណា
មុនចេញធ្វើការ ជាចំណាកស្រុក។
កុំជឿមេខ្យល់ បងប្អូនមានទុក្ខ
ក្រុមហ៊ុនក្នុងស្រុក ក៏ត្រូវពិចារណា។
ពួកខ្លះបញ្ឆោត ឲ្យធ្វើពេស្យា
ពលកម្មខ្លាំងក្លា ខុសច្បាប់ទម្លាប់។
កុំចូលស្រុកគេ ដោយការខុសច្បាប់
ខ្លះត្រូវបាញ់ស្លាប់ គ្មានមេត្តាឡើយ។

អត្ថបទទី៧

# ជីវិតអ្នកក្រ

បទពាក្យ៤

ខ្ញុំក្រខ្សត់ទ្រព្យ    រកព្រឹកសម្រាប់ព្រឹក
លុះល្ងាចខំនឹក    នឹងបានអ្វីចាយ។
ដំបូលប្រក់មេឃ    របែកផ្ទុះធ្លាយ
កូនយំទារបាយ    ខ្ញុំស្រក់ទឹកភ្នែក។
ដីស្រែតិចតួច    ដូនតាបានចែក
ដីមួយចំណែក    ត្រូវគេអូសយក។
សូមជនសប្បុរស    មេត្តាលៃលក
ធ្វើជាជំរក    ឲ្យខ្ញុំរស់ផង។

## អត្ថបទទី៨

# **កុមារពិការ**

## បទពាក្យ៤

កុមារពិការ ជាក្មេងរងគ្រោះ
ត្រូវជួយសង្គ្រោះ ពីទុក្ខវេទនា។
ទាំងអង្គការរដ្ឋ ទាំងជននានា
បញ្ចេញសទ្ធា ដោយជួយឧបត្ថម្ភ។
ត្រូវការសុខភាព រស់ក្នុងសង្គម
ត្រូវការអប់រំ ឲ្យមានវិជ្ជា។
ជាកាតព្វកិច្ច របស់រដ្ឋា
ត្រូវជួយរក្សា កុមារកំព្រា។

អត្ថបទទី៩

# អ្នកកើតរោគអេដ

បទពាក្យ៤

ខ្ញុំកើតរោគអេដ ចម្លងពីប្តី
ខ្ញុំមានកូនបី រស់នៅវេទនា។
ធ្វើការមិនកើត ប្តីស្លាប់យូរយា
ទុកកូនកំព្រា បាត់អ្នករក្សា។
សូមគ្រប់ស្វាមី កុំក្បត់ភរិយា
ឲ្យប្រពន្ធទុក្ខា ដូចជារូបខ្ញុំ។
បងប្អូនប្រុសស្រី សូមជួយឧបត្ថម្ភ
កុំរើសអើងខ្ញុំ ជាអ្នករងគ្រោះ។

អត្ថបទទី១០

# ហឹង្សាក្នុងគ្រួសារ

បទពាក្យ៨

ម្នាលកូនសម្លាញ់បុត្រាបុត្រី
កូនមានស្វាមីនិងមានភរិយា
ត្រូវតែស្មោះត្រង់គោរពសិទ្ធិគ្នា
បើមានបញ្ហាកុំប្រើហឹង្សា។
ប្ដីកុំផឹកស្រាកុំជក់គ្រឿងញៀន
នាំឲ្យបៀតបៀនធ្វើបាបភរិយា
កុំក្បត់ប្រពន្ធលួចមានស្នេហា
នាំឲ្យគ្រួសារកើតការបែកបាក់។
ចម្លងរោគអេដឲ្យដល់ភរិយា
កើតមានរោគាថែមទៀតពីរនាក់

ធ្វើឲ្យកូនចៅដែលគ្នាពឹងពាក់
អស់ទីពំនាក់ទីពឹងអាស្រ័យ។
ប្តីប្រពន្ធនៅក្នុងគ្រួសារ
ប្រព្រឹត្តហឹង្សាត្រូវមានទោសពៃរ៍
តាមច្បាប់កំណត់មិនអាចអភ័យ
ភរិយាស្វាមីមិនត្រូវប្រព្រឹត្តឡើយ។

អត្ថបទទី១១

# **ក្មេងទំនើង**

បទពាក្យ៤

បងប្អូនយុវជន ចូរពិចារណាឡើង
លះភាពទំនើង បងតូចបងធំ។
ចូរកុំប្រព្រឹត្ត ត្រូវស្តាប់ចាស់ទុំ
កុំឲ្យសង្គម កើតមានទុក្ខភ័យ។
ឈប់បង្ករឿង ទោះទីណាក្តី
គួរមានមេត្រី កុំប្រើហឹង្សា។
គួរតែកែខ្លួន ដោយប្រឹងសិក្សា
អប់រំចរិយា ឲ្យល្អវិញឡើង។

អត្ថបទទី១២

# បុណ្យចូលឆ្នាំខ្មែរ

បទពាក្យ៧

ក្នុងថ្ងៃចូលឆ្នាំជនកម្ពុជា
តែងកាត់ជួបគ្នាជូនពរជ័យ
ដោយការស្និទ្ធស្នាលក្នុងឆ្នាំថ្មី
ញាតិមិត្តប្រុសស្រីសូមសុខសាន្ត។
មាតាបិតាលោកនៅរស់
ឬលោកទាំងអស់បានចែកស្ថាន
កូនតែងតបគុណមិនដែលខាន
សូមលោកសុខសាន្តរួចទុក្ខភ័យ។
ពីឆ្នាំថ្មីនេះសិស្សសាលា
ប្រឹងប្រែងសិក្សាឆ្លាតវាងវៃ

ការងារដោយធម៌គ្មានទោសពៃរ៍

នឹងបានជោគជ័យតាមប្រាថ្នា។

សូមប្រសិទ្ធីពរក្នុងឆ្នាំថ្មី

ខេមរាប្រុសស្រីបានសុខា

សូមឲ្យទឹកដីព្រៃព្រឹក្សា

អរិយធម៌កម្ពុជាគង់វង់អើយ។

អត្ថបទទី១៣

# បុណ្យភ្ជុំបិណ្ឌ

បទពាក្យ៤

រដូវភ្ជុំបិណ្ឌ ខ្ញុំនឹកដូនតា
ដែលរំលត់ជន្មា ទៅកាន់លោកនាយ។
បើភ្លាត់គតិ ទៅកាន់អបាយ
សូមលោកប្រែក្លាយ កើតស្ថានសុខា។
កូនឱ្យិសកុសល ដោយចិត្តជ្រះថ្លា
សូមអនុមោទនា រួចចាកទុក្ខភ័យ។
បើកើតសុគតិ បានសុខប្រពៃ
កូនចៅប្រុសស្រី មានចិត្តរីករាយ។

## អត្ថបទទី១៤

# បុណ្យកឋិនទាន

### បទពាក្យ៤

បុណ្យកឋិនទាន មានក្នុងវិន័យ
ព្រះពុទ្ធជិនស្រី ទ្រង់បានអនុញ្ញាត។
ធ្វើត្រូវតាមកាល ចីវរតាមខ្នាត
ព្រះសង្ឃសន្និបាត បានចាំវស្សា។
អានិសង្សបានដល់ ទាយកដើមការ
ព្រះសង្ឃធ្វើការ កាលគ្រងអនុមោទនា។
ជាទានកម្រ ខ្ពង់ខ្ពស់ថ្លៃថ្លា
ជាងទាននានា ក្នុងពុទ្ធសាសនា។

អត្ថបទទី១៥

# បុណ្យពិសាខបូជា

## បទពាក្យ៤

| | |
|---|---|
| បុណ្យពិសាខបូជា | រំលឹកព្រឹត្តិការណ៍ |
| មានបីប្រការ | សម័យព្រះពុទ្ធ។ |
| គឺការប្រសូត | ត្រាស់ដឹងមុះមុត |
| រំលត់ខន្ធក្រោយផុត | នៃព្រះជិនស្រី។ |
| ពេលបុណ្យម្តងៗ | បរិស័ទប្រុសស្រី |
| តាំងចិត្តជាថ្មី | ប្រតិបត្តិធម្មា។ |
| ប្រតិបត្តិតាមធម៌ | ហៅថាបូជា |
| ទើបចាត់ទុកថា | បូជាព្រះពុទ្ធ។ |

អត្ថបទទី១៦

# បុណ្យមាឃបូជា

បទពាក្យ៤

បុណ្យមាឃបូជា រំលឹកព្រឹត្តិការណ៍
ព្រះពុទ្ធឈ្នះមារ ប្រទានឱវាទ។
ព្រះសង្ឃច្រើនអង្គ ប្រជុំសន្និបាត
ស្តាប់ព្រះឱវាទ ពីព្រះធម្មា។
បុព្វហេតុទី២ ទ្រង់ដាក់ជន្មា
នៅបីមាសា រំលត់ខន្ធបរិនិព្វាន។
ទុកធម៌វិន័យ សម្រាប់ទូន្មាន
សព្វសត្វឲ្យបាន រួចវដ្តសង្សារ។

អត្ថបទទី១៧

# បុណ្យចូលវស្សា

បទពាក្យ៤

ការចូលវស្សា ភារកិច្ចព្រះសង្ឃ
ភិក្ខុគ្រប់អង្គ តែងចូលវស្សា។
ក្នុងពេលភ្លៀងធ្លាក់ គ្រប់បីមាសា
ព្រោះពិបាកយាត្រា កាន់ទីនានា។
អំឡុងបីខែ ព្រះសង្ឃភាវនា
តាមផ្លូវវិបស្សនា ឲ្យចិត្តស្អាតថ្លា។
ពួកពុទ្ធបរិស័ទ តែងអនុមោទនា
ការចូលវស្សា របស់ព្រះសង្ឃ។

អត្ថបទទី១៨

# បុណ្យចំរើនព្រះជន្ម

## បទពាក្យ៤

បពិត្រមាតា និងព្រះបិតា
កូនជូនបរិក្ខារ ប្រដាប់ធ្វើបុណ្យ។
ទុកប្រគេនព្រះសង្ឃ ជាការតបគុណ
ជូនលោកធ្វើបុណ្យ ដោយកតញ្ញូ។
ដោយផលបុណ្យនេះ សូមព្រះជន្មយឺនយូរ
សុខភាពបរិបូរណ៍ កម្លាំងខ្លាំងក្លា។
បានលោកធ្វើទាន រក្សាសីលា
ចំរើនវិបស្សនា បន្តទៅទៀត។

អត្ថបទទី១៩

# បុណ្យទក្ខិណានុប្បទាន

បទពាក្យ៤

ខ្ញុំឧទ្ទិសកុសល　　បុណ្យទក្ខិណា
នុប្បទានថ្លៃថ្លា　　ជូនអ្នកមានគុណ។
មាតាបិតា　　អនិច្ចកម្មពីមុន
ដោយអំណាចផលបុណ្យ　　សូមលោកសុខសាន្ត។
បុណ្យមួយផ្នែកទៀត　　ជូនញាតិសន្តាន
ដែលបានចែកស្ថាន　　សូមអនុមោទនា។
កើតចាស់ឈឺស្លាប់　　និងព្រាត់ប្រាសគ្នា
តែងមានធម្មតា　　សត្វក្នុងភពបី។

# កំណាព្យ
# សំរាប់សិស្ស និងនិស្សិត
## វគ្គ៤
**(បានត្រូវយកទៅធ្វើជាបទចំរៀងបូរាណខ្មែរ)**


| | |
|---|---|
| ១. បទថ្វាយផ្កា | ៩៩ |
| ២. ធម៌នមោ | ១០០ |
| ៣. ត្រៃសរណគមន៍ | ១០១ |
| ៤. ពាក្យព្រះពុទ្ធសាសនា | ១០២ |
| ៥. គុណមាតាបិតា | ១០៣ |
| ៦. គុណព្រះពុទ្ធ | ១០៤ |
| ៧. ធម៌ទីពឹង | ១០៥ |
| ៨. ខន្ធ៥ជាតួទុក្ខ | ១០៦ |
| ៩. ពិធីបុណ្យចូលឆ្នាំខ្មែរ | ១០៧ |
| ១០. អត្ថន័យចូលឆ្នាំខ្មែរ | ១០៨ |
| ១១. តម្លៃព្រះពុទ្ធសាសនា | ១០៩ |
| ១២. កម្មផល | ១១០ |

| | |
|---|---|
| ១៣. សីល សមាធិ បញ្ញា | ១១១ |
| ១៤. ព្រហ្មវិហារធម៌ | ១១២ |
| ១៥. រោគពីរប្រការ | ១១៣ |
| ១៦. តម្លៃមនុស្ស | ១១៤ |
| ១៧. គុណព្រះពុទ្ធប្រៀបមកគុណមាតាបិតា | ១១៥ |
| ១៨. ខ្លួនទីពឹងខ្លួន | ១១៦ |

អត្ថបទទី១

# បទថ្វាយផ្កា

ពាក្យ៨

យើងខ្ញុំព្រះអង្គសូមលើកហត្ថា បន្ទន់កាយាក្រាបថ្វាយបង្គំ
ចំពោះព្រះពុទ្ធមានគុណដ៏ធំ តែងតែអប់រំសត្វក្នុងលោកា។
សត្វតែងកើតស្លាប់តាមច្បាប់ធម្មជាតិ
ព្រាត់ប្រាសក្រុមញាតិឃ្លាតក្រុមគ្រួសារ
រងទុក្ខវេទនារន្ធត់ខ្លោចផ្សា គួរឲ្យអនិច្ចាសង្ខារពួកសត្វ។
ត្រូវការព្រះអង្គជួយបំភ្លឺផ្លូវ ឲ្យសត្វដើរទៅដោះស្រាយវិបត្តិ
ទុក្ខសោករោគភ័យឲ្យខ្ចាត់ខ្ចាយបាត់
រំលត់ទុក្ខសត្វប្តូរយកសុខា។
សក្ការបូជាថ្វាយព្រះពុទ្ធអង្គ ព្រមទាំងចិត្តផង់ប្រតិបត្តិធម្មា
សូមសុខចំរើនកើតមានគ្រប់គ្នា ឆ្លងវដ្តសង្សារដល់និព្វានហោង។

អត្ថបទទី២

# **ធម៌នមោ**

ពាក្យ៨

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
សូមនមស្ការដោយគារវៈ ដោយចិត្តស្មោះស្ម័គ្រចំពោះព្រះពុទ្ធ។
នាមសម្ពុទ្ធោខាងដើមសម្មា បកប្រែន័យថាត្រាស់ដឹងមោះមុត
ជាព្រះសម្ពុទ្ធព្រះទ័យបរិសុទ្ធ ថ្លាស្អាតបំផុតនាមអរហតោ។
នាមភគវតោទ្រង់អាសូរដល់សត្វ ប្រាប់ធម៌កំចាត់អវិជ្ជាមោហោ
សង្ខេបព្រះនាមក្នុងធម៌នមោ មានន័យបរិបូណ៌នាមក្នុងពុទ្ធគុណ។
គម្រប់បីដង បង្គំវន្ទា ព្រះពុទ្ធឈ្នះមារព្រះអង្គមានបុណ្យ
ខ្ញុំសូមបានសុខរួចបាបពីមុន សារផលបុណ្យសម្រេចនិព្វានហោង។

អត្ថបទទី៣

# ត្រៃសរណគមន៍

ពាក្យ៧

ពុទ្ធំព្រះនាម អ្នកត្រាស់ដឹង សរណៈទីពឹង ខ្ញុំព្រះករុណា
ជាទីជម្រកសព្វសត្វា ដែលមានប្រាថ្នារំដោះទុក្ខ ។
ធម្មំព្រះធម៌ជាម៌ាគា នាំសត្វនានាកាន់ទីសុខ
បើប្រតិបត្តិតាមតទៅមុខ នឹងបានក្តីសុខផុតទុក្ខា ។
សង្ឃំភេទប្រសើរថ្លៃបរិសុទ្ធ តំណាងព្រះពុទ្ធតសាសនា
ទុកជាទីពឹងគ្រប់រូបា បានស្តាប់ទេសនាព្រះធម្មា ។
ព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃ ទាំងបីព្រះអង្គ ចែងច្បាស់ថា
ជាបាវចនា ពុទ្ធសាសនា ខ្ញុំព្រះអង្គគ្រប់គ្នា យកជាទីពឹង។

អត្ថបទទី៤

# ពាក្យព្រះពុទ្ធសាសនា

ពាក្យ៧

មិត្តរួមសាសនាឆ្លាតវាងវៃ ខ្ញុំសូមអភ័យសួរប្រស្នា
អំពីពាក្យថាពុទ្ធសាសនា មានន័យយ៉ាងណាត្រូវបំផុត ។
ពាក្យពុទ្ធសាសនាជាបាលី សូមប្រែសេចក្ដីជាខ្មែរសុទ្ធ
ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឲ្យសត្វឆ្លងផុតពីភពបី ។
ខ្ញុំសូមអរគុណនឹងមិត្តណាស់ បកប្រែបានច្បាស់អស់សង្ស័យ
ចុះពាក្យព្រះពុទ្ធបានដល់អ្វី សូមប្រែសេចក្ដីឲ្យជាក់ច្បាស់។
អ្នកត្រាស់ដឹងធម៌អរិយសច្ច៤ ត្រឹមត្រូវតាមក្បួនជាអ្នកត្រាស់
ទើបហៅព្រះពុទ្ធត្រូវច្បាស់លាស់ ប្រាប់ផ្លូវរំដោះទៅនិព្វាន ។

អត្ថបទទី៥

# គុណមាតាបិតា

ពាក្យ៤

មិត្តពុទ្ធសាសនិក មានសន្តានចិត្តបុណ្យ
សូមពន្យល់ពាក្យគុណ តាមគម្ពីរដីកា ។
គុណគឺសេចក្តីល្អ មានចំពោះមនុស្សណា
សាងល្អថ្លៃថ្លា តាមព្រះធម្មា ។
ចុះគុណមាតា បិតាទ្វេហា
ស្ថិតនៅត្រង់ណា សូមប្រាប់សេចក្តី ។
គុណស្ថិតត្រង់លោក មានចិត្តមេត្រី
ចំពោះកូនប្រុសស្រី ចិញ្ចឹមរក្សា ។

អត្ថបទទី៦

# គុណព្រះពុទ្ធ

ពាក្យ៤

សូមមិត្តពន្យល់ ពីគុណព្រះពុទ្ធ
សង្ខេបបំផុត មានប៉ុន្មានប្រការ ។
គុណរបស់ព្រះពុទ្ធ ជាគោលខ្លឹមសារ
មានបីប្រការ គម្ពីរបានចែង ។
សូមមិត្តរៀបរាប់ ឲ្យបានជាក់ស្តែង
គម្ពីរបានចែង ទាំងបីប្រការ ។
មួយបញ្ញាគុណ ពីរព្រះទ័យស្អាតថ្លា
បីគុណករុណា រួមគុណបីយ៉ាង ។

អត្ថបទទី៧

# ធម៌ទីពឹង

ពាក្យ៤

| | |
|---|---|
| ពាក្យពុទ្ធភាសិត | អត្តទីបា |
| ទីពឹងអាត្មា | ធ្វើអំពើល្អ ។ |
| ធម្មទីបា | ដើរតាមព្រះធម៌ |
| មាគ៌ាបវរ | ព្រះពុទ្ធសំដែង ។ |
| ពឹងទាំងពីរនេះ | បានផលជាក់ស្តែង |
| បើបានប្រឹងប្រែង | យកជាទីពឹង ។ |
| អ្វីក្រៅពីនេះ | គប្បីយល់ដឹង |
| ពុំមែនទីពឹង | អ្នករាល់គ្នាឡើយ ។ |

អត្ថបទទី៨

# ខន្ធ៥ជាតួទុក្ខ

ពាក្យ៤

ខ្លួនគឺខន្ធ៥ រូបវេទនា
សញ្ញាសង្ខារ វិញ្ញាណជាប្រាំ ។
តែងមានលក្ខណៈ ជាអនិច្ចំ
ទីពីរទុក្ខំ បីអនត្តា ។
ពិចារណាឃើញច្បាស់ តាមផ្លូវវិបស្សនា
ជាតួទុក្ខា ត្រូវកំណត់ដឹង ។
សត្វនៅក្នុងលោក គួរតែខំប្រឹង
ព្យាយាមរំពឹង ឈោងយកនិព្វាន ។

អត្ថបទទី៩

# ពិធីបុណ្យចូលឆ្នាំខ្មែរ

កាកគតិ

បុណ្យចូលឆ្នាំខ្មែរ  មានមកហូរហែ  ព្រេងនាយដូនតា
ដោយខ្មែរគោរព  ព្រះពុទ្ធសាសនា  ពិធីនានា
ធ្វើតាមព្រះធម៌ ។
បីយប់បីថ្ងៃ  ជាតិខ្មែរប្រុសស្រី  រីករាយត្រេកអរ
នាំគ្នាទៅវត្ត  ពេលយប់ស្តាប់ធម៌  ពេលថ្ងៃបន្ត
ធ្វើកិច្ចសាសនា ។
នាំគ្នារាប់បាត្រ  តាំងចិត្តឲ្យស្អាត  រក្សាសីលា
ឲ្យបានកុសល  ជូនញាតិកា  មាតាបិតា
ដែលចែកស្ថានទៅ ។
បង្គំវន្ទា  មាតាបិតា  ដែលលោករស់នៅ
សូមសុខចំរើន  ជាម្លប់កូនចៅ  រក្សាពង្សផៅ
នៃវង្សខេមរា ។

អត្ថបទទី១០

# **អត្ថន័យចូលឆ្នាំខ្មែរ**

កាកគតិ

ចូលមកឆ្នាំថ្មី ជាតិខ្មែរប្រុសស្រី គួរពិចារណា
បញ្ហាជីវិត ត្រូវរៀបផែនការ ប្រសើរថ្លៃថ្លា
ល្អជាងឆ្នាំចាស់ ។
ត្រូវសំអាតចិត្ត ឲ្យបានប្រណីត តាមពុទ្ធតម្រាស់
ខ្មែរគ្រប់ឋានៈ ប្រុសស្រីក្មេងចាស់ បានសុខជាក់ច្បាស់
កម្ពុជាលោកីយ៍ ។
បើមានខុសឆ្គង មួយឆ្នាំកន្លង មិនយកទោសពៃរ៍
ខ្មែរចេះអត់ឱន មេត្តាប្រណី ជូនពរឆ្នាំថ្មី
សូមសុខចុំថ្កើង ។
ព្រលឹងដូនតា ស្រែកហៅខេមរា ឲ្យភ្ញាក់ក្រោកឡើង
ស្មារតីរួបរួម ការពារជាតិយើង រុងរឿងចុំថ្កើង
ស្ថិតស្ថេរគង់វង់។

អត្ថបទទី១១

# តម្លៃព្រះពុទ្ធសាសនា

ពាក្យ៧

តម្លៃទី១ពុទ្ធសាសនា បានដល់មាគ៌ាមគ្គ៨
ជាផ្លូវកណ្ដាលឆ្លងភពបី ដែលព្រះជិនស្រីបានត្រាស់ដឹង។
តម្លៃទី២ព្រះនិព្វាន ទុក្ខសោកប៉ុន្មានរលត់សូន្យឈឹង
មានតែបរមសុខជាទីពឹង គួរតែខំប្រឹងឲ្យកើតមាន។
តម្លៃទីបីធម៌អហិង្សា មានចិត្តមេត្តាក្នុងសន្ដាន
មិនបៀតបៀនគ្នាមនុស្សគ្រប់ប្រាណ ទើបសុខក្សេមក្សាន្តគ្រប់រូបា។
រួបរួមតម្លៃគឺមគ្គ៨ និព្វានផុតភ័យផុតសោកា
មិនបៀតបៀនគ្នាកាន់អហិង្សា ទើបក្នុងលោកាបានសុខសាន្ត។

អត្ថបទទី១២

## កម្មផល

ពាក្យ៤

ជឿពុទ្ធសាសនា គឺជឿកម្មផល
សុខទុក្ខបានផ្តល់ តាមកម្មខ្លួនចាត់។
កម្មគឺចេតនា របស់មនុស្សសត្វ
ជាអ្នកអារកាត់ វាសនាគ្រប់ប្រាណ។
កម្មជាមរតក ជាផៅសន្តាន
សុខទុក្ខប៉ុន្មាន ស្ថិតលើកម្មផល។
ជាច្បាប់ធម្មជាតិ លក្ខណៈសកល
តែងតែឲ្យផល ត្រឹមត្រូវតាមកម្ម។

អត្ថបទទី១៣

# សីល សមាធិ បញ្ញា

ពាក្យ៤

សីលសមាធិ ព្រមទាំងបញ្ញា
ជាមជ្ឈិមា សង្ខេបមគ្គ៨។
ទីមួយគឺសីល វៀរចាកទោសពៃរ៍
តាមព្រះវិន័យ ផ្លូវកាយវាចា។
ពីរសមាធិ សង្កត់ទោសា
ធម៌នីវរណា រារាំងផ្លូវចិត្ត។
ទីបីបញ្ញា លះកិលេសយ៉ាងល្អិត
ដេកត្រាំក្នុងចិត្ត របស់មនុស្សសត្វ។

អត្ថបទទី១៤

# ព្រហ្មវិហារធម៌

ពាក្យ៤

ព្រហ្មវិហារធម៌ មួយគឺមេត្តា
ចិត្តរាប់អានគ្នា ស្មោះអស់ពីចិត្ត។
ពីរករុណា មានចិត្តអាណិត
អ្នកមានទុក្ខពិត ខំជួយរំដោះ។
បីមុទិតា មានចិត្តល្អស្មោះ
ត្រេកអរចំពោះ អ្នកសុខសប្បាយ។
បួនឧបេក្ខា ចិត្តមិនខ្វល់ខ្វាយ
សុខទុក្ខទាំងឡាយ ស្រេចកម្មមនុស្សសត្វ។

អត្ថបទទី១៥

# រោគពីរប្រការ

ពាក្យ៤

រោគពីរប្រការ រោគកាយរោគចិត្ត
រោគនេះមានពិត មនុស្សគ្រប់រូបា។
រោគកើតក្នុងកាយ តាមពុទ្ធសាសនា
ត្រូវថែរក្សា ព្យាបាលដោយថ្នាំ។
ឯរោគផ្លូវចិត្ត គ្រប់គ្នាចងចាំ
ត្រូវកែដោយថ្នាំ បានដល់ព្រះធម៌។
ត្រូវអប់រំចិត្ត ឲ្យបរិសុទ្ធល្អ
ចាក់ផ្ទុះព្រះធម៌ រោគចិត្តជាហោង។

អត្ថបទទី១៦

# តម្លៃមនុស្ស

ពាក្យ៤

តម្លៃនៃមនុស្ស ស្ថិតលើគុណសម្បត្តិ
ព្រះពុទ្ធបានចាត់ មានពីរប្រការ ។
វិជ្ជាសម្បត្តិ អ្នកមានវិជ្ជា
ចំណេះប្រាជ្ញា ផ្លូវលោកផ្លូវធម៌។
ចរិយាសម្បត្តិ មានចរិយាល្អ
អ្នកមានសីលធម៌ ប្រចាំកាយា។
គុណសម្បត្តិទាំងពីរ មានក្នុងមនុស្សណា
លោកចាត់ទុកថា មនុស្សមានតម្លៃ។

អត្ថបទទី១៧

# គុណព្រះពុទ្ធប្រៀបមកគុណមាតាបិតា

ពាក្យ៤

ព្រះពុទ្ធមានគុណ សង្ខេបបីប្រការ
គុណករុណា អាណិតសត្វបំផុត។
វិសុទ្ធិគុណ ព្រះទ័យបរិសុទ្ធ
បញ្ញាមោះមុត លើលោកាចារ្យ។
ឯគុណមាតា និងគុណបិតា
មានព្រហ្មវិហារ តែទៅលើបុត្រ។
ព្រះពុទ្ធពិសេស ត្រង់ក្តីបរិសុទ្ធ
មានញាណថ្លាមុត ប្រោសសត្វទូទៅ។

អត្ថបទទី១៨

# ខ្លួនទីពឹងខ្លួន

ពាក្យ៤

ខ្លួនទីពឹងខ្លួន ព្រះពុទ្ធសំដែង
ត្រូវពឹងខ្លួនឯង ធ្វើអំពើល្អ ។
ពឹងអ្នកដទៃ ត្រឹមជួយបន្ត
មិនអាចធ្វើល្អ ជួសគ្នាបានឡើយ។
បើចង់ផុតទុក្ខ ឆ្លងរួចដល់ត្រើយ
មិនត្រូវកន្តើយ ប្រតិបត្តិធម្មា។
ឯអ្នកធ្វើបាប ត្រូវមានទោសា
ពុំអាចជនណា ទទួលជួសឡើយ។